# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេត

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាន ទីឡុង**

លោក **ថ្លាង ភូរ៉ូវិត**

ណែនាំដោយ

លោក **ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេត

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាន ទីឡុង**

លោក **ថ្លាង ភូរ៉ូវិត**

ណែនាំដោយ

លោក **ហោ សុភ័ណ្ឌា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សាន ទីឡុង** និងឈ្មោះ **ថ្លាង ភូរ៉ូទិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីររូបសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ❖ **លោកឪពុក អ្នកម្តាយ** ដែលជាអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើតដល់រូបខ្ញុំទាំងពីរ និងបានចិញ្ចឹមបីបាច់ថែរក្សា ការពារ អប់រំ ទូន្មានប្រៀនប្រដៅ ក៏ដូចជាផ្តល់នៅដំបូន្មានយ៉ាងយកចិត្តទុកដាក់បំផុត ចាប់តាំងពីចាប់កំណើតរហូតមកដល់បច្ចុប្បន្ន។ ជាពិសេសនោះ គឺការផ្គត់ផ្គង់ផ្នែកសម្ភារៈគ្រប់បែបយ៉ាង ទំនុកបម្រុង ជ្រោមជ្រែង លើកទឹកចិត្តឱ្យកូនបានសិក្សារៀនសូត្រតាំងពីបឋមសិក្សារហូតដល់បានបញ្ចប់ការសិក្សា។
- ❖ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំង លោក លោកស្រីសាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងដឹកនាំ ណែនាំ និងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ចំពោះនិស្សិតទាំងអស់កន្លងមក។
- ❖ ជាពិសេស សូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ **លោក ហោ សុភ័ណ្ឌា** ដែលបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការពន្យល់ណែនាំ បង្ហាត់បង្ហាញ និងជួយកែតម្រូវរាល់កំហុសឆ្គងនៅក្នុងដំណើរការនៃការសរសេរសារណារបស់យើងខ្ញុំទាំងពីរតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការសរសេរសារណាមួយនេះបានដោយជោគជ័យ។

ជាចុងក្រោយយើងខ្ញុំទាំងពីររូប សូមគោរពដល់អ្នកមានគុណទាំងពីរ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់គ្នាទទួលបានសេចក្តីសុខ សេចក្តីចម្រើនព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំរួចមក យើងខ្ញុំមានកិត្តិយសដែលមានសិទ្ធិក្នុងការសរសេរសារណា ឬចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ។ ក្រោយពីបានពិភាក្សាគ្នាយើងខ្ញុំបានជ្រើសរើសយកនូវប្រធានបទ«**តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេត**» មកធ្វើជាប្រធានបទដើម្បីបញ្ចប់ការសិក្សានេះ។ កម្មវត្ថុសំខាន់មួយទៀត គឺចង់ឱ្យនិស្សិតជំនាន់ក្រោយ ក៏ដូចជាសាធារណៈជន បានយល់ដឹងនិងយកចិត្តទុកដាក់អំពីតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាបញ្ហាប្រឈម និងដំណោះស្រាយរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលស៊ើបអង្កេត ព្រោះនៅក្នុងដំណាក់កាលស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌អាចនឹងជួបនៅបញ្ហាប្រឈមមួយចំនួននៅក្នុងការបំពេញតួនាទី និងភារកិច្ច។

យើងខ្ញុំសង្ឃឹមថា សារណាមួយនេះ នឹងក្លាយជាឯកសារមួយយ៉ាងសំខាន់ និងជាប្រយោជន៍ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្រាវជ្រាវ និងរួមចំណែកក្នុងការពង្រឹង និងលើកស្ទួយលើវិស័យយុត្តិធម៌ក៏ដូចជាស្ថាប័ននគរបាលយុត្តិធម៌។ ជាមួយនឹងសារណាមួយនេះផងដែរ យើងជឿជាក់ថាឯកសារមួយច្បាប់នេះអាចពង្រឹងដល់មុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ របស់និស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានបំណងចង់ស្វែងយល់អំពីតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាបញ្ហាប្រឈម និងដំណោះស្រាយរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងដំណាក់កាលស៊ើបអង្កេត។

បើទោះបីជាសារណាមួយនេះ បានលេចចេញជារូបរាងរួចមកក៏ដោយ យើងជឿជាក់ថាសារណាមួយក្បាលនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ដូច្នេះហើយយើងខ្ញុំរីករាយទទួល និងស្វាគមន៍នៅមតិរិះគន់គ្រប់សព្វបែបយ៉ាង ក្នុងគោលបំណងដើម្បីស្ថាបនាដល់យើងខ្ញុំ។ យើងខ្ញុំសូមអរគុណនៅការរិះគន់ដើម្បីកែលម្អនូវសារណាមួយនេះ ឱ្យបានកាន់តែប្រសើរឡើង។

# មាតិកា

**សេចក្តីផ្តើម** ................................................ ១

# ជំពូកទី១

# មន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១៖ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌** ................................ ២

**១.១.មន្ត្រីនគរបាលយុត្តិធម៌** ................................................ ២

១.១.១.ការទទួលបាននីតិសម្បទាដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ................ ២

១.១.១.១.ការប្រឡងប្រជែងយកសញ្ញាបត្រជាន់ខ្ពស់ ................................ ២

១.១.១.២.ការទទួលបានតាមឋានន្តរសក្តិ និងមុខងារ ................................ ៣

១.១.១.៣.ការទទួលបានដោយស្វ័យប្រវត្តិ ................................ ៥

១.១.២.ការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................ ៦

**១.២.ភ្នាក់ងារនគរបាលយុត្តិធម៌** ................................................ ៦

១.២.១.លក្ខខណ្ឌដើម្បីក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌ ................................ ៦

១.២.១.១.តាមលក្ខខណ្ឌ ................................................ ៦

១.២.១.២.តាមរយៈការធ្វើសម្បថ ................................................ ៧

១.២.២.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ................................ ៧

**១.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ** ................................................ ៧

១.៣.១.ការទទួលបាននីតិសម្បទាតាមរយៈច្បាប់ដោយឡែក ................................ ៨

១.៣.១.១.ការទទួលតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ...... ៨

១.៣.១.២.តាមរយៈច្បាប់ស្តីពីព្រៃឈើ ................................................ ៨

១.៣.១.៣.តាមរយៈច្បាប់ស្តីពីគយ ................................................ ៨

១.៣.២.សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ................................ ៩

១.៣.២.១.ទីកន្លែងដែលត្រូវធ្វើសម្បថ ................................................ ៩

១.៣.២.២.នត្ថិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត..... ៩

**ផ្នែកទី ២ ៖ តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១០**
**២.១.ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ........ ១០**
២.១.១.ការចុះទៅកាន់ទីកន្លែងកើតហេតុ ........ ១០
២.១.២.ការឃាត់ខ្លួន ........ ១១
២.១.៣.ការឆែកឆេរ ........ ១២
២.១.៤.ការចាប់យកវត្ថុតាង ........ ១៣
២.១.៥.ការស្តាប់ចម្លើយ ........ ១៤
២.១.៦.ការត្រួតពិនិត្យខាងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ........ ១៥
២.១.៧.ការបញ្ជូនកំណត់ហេតុវត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ........ ១៥
**២.២.ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង ........ ១៥**
២.២.១. វិធាននៃកាស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសមិនជាក់ស្តែង........ ១៦
២.២.២. វិធានការក្នុងការឃាត់ខ្លួន និងបញ្ជូនខ្លួនជនដែលត្រូវបានឃាត់ខ្លួន ........ ១៧
២.២.៣.កំណត់ហេតុក្នុងការស្តាប់ចម្លើយ ........ ១៧
**២.៣.ការស៊ើបអង្កេតតាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ........ ១៨**
២.៣.១.និយមន័យ ........ ១៨
២.៣.២.លក្ខណៈទូទៅ ........ ១៨
២.៣.៣.កិច្ចអនុវត្តនានា ........ ១៩

## ជំពូកទី២

## បញ្ហាប្រឈម និងដំណោះស្រាយ របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត

**ផ្នែកទី ១៖ បញ្ហាប្រឈមក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ២២**
**១.១. កង្វះខាតវត្ថុតាងក្នុងការស៊ើបអង្កេត ........ ២២**
១.១.១.សាក្សីមិនសហការ ឬមិនមានសាក្សីដែលបានឃើញហេតុការណ៍........ ២៣
១.១.២.ការបាត់បង់ភស្តុតាង ឬវត្ថុតាង ........ ២៣
**១.២.កត្តាមធ្យោបាយក្នុងការចុះស៊ើបអង្កេត........ ២៤**
១.២.១.មធ្យោបាយសម្ភារៈសម្រាប់ធ្វើការស៊ើបអង្កេត ........ ២៤
១.២.២.មធ្យោបាយក្នុងការធ្វើដំណើរដើម្បីចុះទៅកន្លែងកើតហេតុ........ ២៥
១.២.៣.កត្តាថវិកា ........ ២៥

**១.៣.កង្វះធនធានរបស់មន្ត្រីនគរបាលយុត្តិធម៌**......២៦
១.៣.១.កង្វះសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ......២៦
១.៣.២.កង្វះបទពិសោធន៍ ឬកង្វះជំនាញ ......២៧
១.៣.៣.ការអនុវត្តខុសនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌......២៧
**ផ្នែកទី២៖ ដំណោះស្រាយ** ......២៨
**២.១.ការពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌**......២៨
២.១.១.ការបើកវគ្គបណ្តុះបណ្តាល......២៨
២.១.២.តាមរយៈការធ្វើសិក្ខាសាលា ......២៩
**២.២.ផ្តល់ជំនួយបន្ថែមលើគ្រប់មធ្យោបាយនៃការស៊ើបអង្កេត** ......២៩
២.២.១.ជំនួយជាថវិកា......៣០
២.២.២.ជំនួយជាសម្ភារៈ......៣០
**២.៣.យន្តការពង្រឹងការអនុវត្តច្បាប់** ...... ៣១
២.៣.១.ការលុបបំបាត់អំពើពុករលួយ ......៣១
២.៣.២.ការលុបបំបាត់វប្បធម៌ការអន្តរាគមន៍ ......៣១
២.៣.៣.ការលុបបំបាត់វប្បធម៌និទណ្ឌភាព......៣១
**សេចក្តីសន្និដ្ឋាន**...... ៣៣
**អនុសាសន៍**...... ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនសម័យកាល ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ ដើម្បីក្លាយជារដ្ឋមួយដែលមានការអភិវឌ្ឍឆ្ពោះទៅមុខ។ ដើម្បីឱ្យរដ្ឋមួយមានការអភិវឌ្ឍឆ្ពោះទៅមុខបាន លុះត្រាតែរដ្ឋនោះមានសន្តិសុខក្នុងសង្គម និងសណ្តាប់ធ្នាប់សាធារណៈល្អ ហេតុនេះហើយទើបថ្នាក់ដឹកនាំនីមួយៗជាពិសេសស្ថាប័ននីតិបញ្ញត្តិកំពុងបានខិតខំប្រឹងប្រែងក៏ដូចជាការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីឱ្យប្រជាពលរដ្ឋគោរពតាម និងផ្តល់ភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋ។ ក្នុងនោះផងដែរ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការបានចូលរួមចំណែកក្នុងការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវកាតព្វកិច្ចរបស់ខ្លួនដើម្បីឱ្យរដ្ឋទទួលបាននៅសុខសន្តិភាព ហើយស្ថាប័នទាំងពីរបានបង្កើតនៅអង្គភាពមួយដែលមានសមត្ថភាពអាចចុះប្រតិបត្តិការនៅកន្លែងកើតហេតុភ្លាមៗ ដែលអង្គភាពនោះហៅថាមន្ត្រីនគរបាលយុត្តិធម៌។ មួយវិញទៀត អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ពិតជាមានសារៈសំខាន់ផងដែរ ចំពោះការអនុវត្តច្បាប់ដែលជាជំនួយការរបស់អំណាចតុលាការក្នុងការស៊ើបអង្កេតបទល្មើសដែលកើតមានឡើង។ ទន្ទឹមនឹងនេះផងដែរ នៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌អាចទទួលរងនូវបញ្ហាប្រឈមមួយចំនួនដែលបង្កឱ្យមានភាពរាំងស្ទះក្នុងការអនុវត្តច្បាប់ ក៏ដូចជាការបំពេញភារកិច្ច។

គោលបំណងក្នុងការស្រាវជ្រាវប្រធានបទនេះ យើងខ្ញុំទាំងពីរ គឺចង់ស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីសមាសភាព តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាពិសេសនោះគឺឱ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែស៊ីជម្រៅ អំពីបញ្ហាប្រឈមរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត និងដើម្បីឱ្យមានការចូលរួមសហការនៅក្នុងការអនុវត្តភារកិច្ច។

**តើមន្ត្រីនគរបាលយុត្តិធម៌ជានរណា? តើមន្ត្រីនគរបាលមានតួនាទីអ្វីខ្លះ? តើនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌មានបញ្ហាប្រឈម និងមានដំណោះស្រាយអ្វីខ្លះ ?**

ដើម្បីឆ្លើយនៅចំណោទបញ្ហាទាំងនេះ យើងខ្ញុំនឹងធ្វើការបកស្រាយឱ្យបានលម្អិតនៅក្នុងខ្លឹមសារខាងក្រោម។ ហើយដើម្បីជាមូលដ្ឋានក្នុងការបកស្រាយ ឱ្យបានក្បោះក្បាយយើងបានធ្វើការបែកចែកជា ២ ជំពូក ដូចតទៅ ៖

- **ជំពូកទី១** ៖ មន្ត្រីនគរបាលយុត្តិធម៌ដែលក្នុងនោះ យើងខ្ញុំបានលើកឡើងអំពីសមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ តួនាទី និងសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ។
- **ជំពូកទី២** ៖ បញ្ហាប្រឈម និងដំណោះស្រាយ របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតដែលក្នុងជំពូកនេះយើងខ្ញុំបានធ្វើការលើកឡើងអំពី បញ្ហាប្រឈមនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងដំណោះស្រាយលើបញ្ហាប្រឈមមួយចំនួន។

# ជំពូកទី១

# មន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី១

# មន្ត្រីនគរបាលយុត្តិធម៌

## ផ្នែកទី១៖ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌

បើយោងទៅតាមមាត្រា៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ចំពោះនគរបាលយុត្តិធម៌ ត្រូវបានបែងចែកសមាសភាពជាបីគឺ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ។[១] ដោយសមាសភាពទាំងបីនេះត្រូវបានដឹកនាំ និងសម្របសម្រួលដោយព្រះរាជអាជ្ញា ប៉ុន្តែនៅក្នុងករណីមួយផ្សេងទៀតគឺនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានចុះអនុវត្តដីកា ចាត់ឱ្យស៊ើបសួរជំនួសគឺស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរវិញម្តង។

### ១.១.មន្ត្រីនគរបាលយុត្តិធម៌

មុននឹងឈានទៅដល់ការបកស្រាយអំពីការទទួលបាននៅគុណសម្បត្តិដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ យើងនឹងធ្វើការពន្យល់អំពីនិយមន័យនៃមន្ត្រីនគរបាលយុត្តិធម៌ជាមុនសិន។ មន្ត្រីនគរបាលយុត្តិធម៌គឺជាភ្នាក់ងារមួយក្រុមនៃនគរបាល ដែលមានតួនាទីទទួលបន្ទុកការពារ ទប់ស្កាត់ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌដែលរួមទាំងបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ និងថៃរក្សា សណ្តាប់ធ្នាប់ក្នុងសង្គម។

#### ១.១.១.ការទទួលបាននីតិសម្បទាដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌

ដើម្បីទទួលបាននីតិសម្បទាក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការឆ្លងកាត់បីដំណាក់កាលដូចជាការប្រឡងប្រជែងយកសញ្ញាបត្រជាន់ខ្ពស់ ការទទួលបានតាមឋានន្តរសក្តិ ការធ្វើសម្បថ។

##### ១.១.១.១.ការប្រឡងប្រជែងយកសញ្ញាបត្រជាន់ខ្ពស់

មុននឹងឈានទៅដល់ ការទទួលបាននីតិសម្បទាគ្រប់គ្រាន់ក្នុងការមាននៅឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ នោះត្រូវមានការប្រឡងប្រជែងដើម្បីទទួលបានសញ្ញាបត្រជាន់ខ្ពស់ខាងមន្ត្រីនគរបាលយុត្តិធម៌ជាមុនសិន។

**ក.លក្ខខណ្ឌក្នុងការប្រឡងប្រជែងយកសញ្ញាបត្រ**

ចំពោះបុគ្គលដែលមានសិទ្ធិគ្រប់គ្រាន់ក្នុង ការប្រឡងប្រជែងយកសញ្ញាបត្រជាន់ខ្ពស់មាន ៖

- មន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិចាប់ពី អនុសេនីយ៍ត្រីឡើងទៅដែលបានបំរើការងារយ៉ាងតិចបំផុត ២ ឆ្នាំក្នុងនគរបាលជាតិហើយ។[២]

[១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៥៧។

[២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦០ វាក្យខណ្ឌទី១។

- នាយទាហានដែលបានបម្រើការងារក្នុងកងរាជអាវុធហត្ថ ដែលបានបម្រើការងារយ៉ាងតិច ២ ឆ្នាំក្នុងកងរាជអាវុធហត្ថ។ នៅពេលដែលពួកគាត់បានបំពេញនៅលក្ខខណ្ឌដែលបានរៀបរាប់ខាងលើរួចហើយនោះពួកគាត់ និងទទួលបានសិទ្ធិក្នុងការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ដើម្បីទទួលបាននីតិសម្បទាពេញលេញជាមន្ត្រីនគរបាលយុត្តិធម៌។

**ខ.បែបបទនៃការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់**

នៅក្នុងបែបបទនៃការប្រឡងយកសញ្ញាបត្រ កងកម្លាំងទាំងពីរស្ថាប័នត្រូវឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈដែលមានគណៈមេប្រយោគពីស្ថានប័នជំនាញ ដើម្បីធ្វើការអង្កេតមើលដែលរួមមានវិញ្ញាសារជាមូលដ្ឋានដូចខាងក្រោម៖

- វិញ្ញាសារស្តីពីនីតិព្រហ្មទណ្ឌទូទៅ
- វិញ្ញាសារស្តីពីនីតិវិធីព្រហ្មទណ្ឌ
- វិញ្ញាសារស្តីពីករណីកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ដែលមានតាក់តែងដោយអង្គការសហប្រជាជាតិ។

ចំពោះគណៈមេប្រយោគនៃការប្រឡង គឺស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ។[៣]

❖ ទាក់ទងនឹងមន្ត្រីនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ។

❖ ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ។

**១.១.១.២.ការទទួលបានឋានន្តរសក្តិ និងមុខងារ**

ដោយយោងទៅតាមមាត្រា ៦០ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងលើចំណុចជាច្រើនទាក់ទងទៅនឹងការទទួលបានឋានន្តរសក្តិ និងមុខងាររបស់មន្ត្រីនគរបាលយុត្តិធម៌។[៤] ដើម្បីឱ្យមានភាព

[៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦២។

[៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦០ វាក្យខណ្ឌទី៣។

ច្បាស់លាស់យើងនឹងធ្វើការពន្យល់បន្ថែម លើចំណុចមួយចំនួនដូចជា អភិបាល អភិបាលរង ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

❖ **អភិបាល និងអភិបាលរង ខេត្ត ក្រុង ស្រុក ខណ្ឌ**

អភិបាល និងអភិបាលរង ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងឡើងដោយស្របតាមមាត្រា១៤៣ លក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ខណ្ឌ។[៥]

❖ **មេឃុំ និងចៅសង្កាត់**

ក. មេឃុំ ចៅសង្កាត់ គឺជាក្រុមប្រឹក្សា ដែលមានឈ្មោះរបស់គាត់ស្ថិតនៅលើគេបង្អស់ក្នុងបញ្ជីបេក្ខជនដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេបង្អស់ ក្នុងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់។

ខ. ប្រធាន និងអនុប្រធាន ព្រមទាំងនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកផ្នែកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនេះ

- នាយកដ្ឋាននគរបាលព្រំដែន (សម្រាប់បទល្មើសឆ្លងដែន)
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា៖

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងកំរិតស្រាល ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

[៥] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋាបាល រាជធានី ខេត្ត ក្រុង ខណ្ឌ។

- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម
- ការិយាល័យជនបរទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ខណ្ឌ។

ជ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរណ៍។

ឈ. ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ

ញ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍

ដ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ (សម្រាប់បទល្មើសព្រហ្មទណ្ឌ)

ឋ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ រាជធានី ខេត្ត ស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌដែលត្រូវបង្កើតឡើងក្នុងករណីចាំបាច់។

ចំពោះរដ្ឋមន្ត្រីជាអាណាព្យាបាល នៃមន្ត្រីនគរបាលយុត្តិធម៌ ឬនាយទាហានកងរាជអាវុធហត្ថទាំងឡាយដែលបានលើកឡើងនៅក្នុងចំណុច **១.១.១.១.** និង **១.១.១.២** នៃសារណានេះជាអ្នកមានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថ ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**១.១.១.៣.ការទទួលបានដោយស្វ័យប្រវត្តិ**

ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ក៏អាចទទួលបានដោយស្វ័យប្រវត្តិផងដែរ។ ចំពោះចំណុចនេះមានន័យថា ជនទាំងឡាយណាដែលបានបំពេញនូវលក្ខខណ្ឌមុនក្រមនេះចូលជាធរមាននោះមានការផ្តល់ជូនដល់គាត់នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។ យើងនឹងលើកយកមកសិក្សានូវបុគ្គល២ (ពីរ) ប្រភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

**ក. នាយនគរបាលជាតិ**

សំដៅទៅលើនាយនគរបាលជាតិដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ស្តីពីមន្ត្រីនគរបាលយុត្តិធម៌ មុនពេលក្រមនេះចូលជាធរមាន ដែលត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយនឹងត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

**ខ. នាយទាហាននៃកងរាជអាវុធហត្ថ**

សំដៅទៅលើនាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្រនៃមន្ត្រីប៉ូលិសតុលាការ មុនពេលក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។[៦]

### ១.១.២ការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីសេចក្តីប្រកាសរួមនៃការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌រួចហើយ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចបំពេញនៅមុខងារ ឬតួនាទីបានភ្លាមៗនោះទេ គឺត្រូវឆ្លងកាត់ការធ្វើសម្បថ ឬការធ្វើសច្ចាប្រណិធានជាមុនសិន។ ហើយការសម្បថត្រូវធ្វើឡើងនៅសាលាឧទ្ធរណ៍។ សម្រាប់មន្ត្រីនគរបាលគ្រប់រូបត្រូវ សម្បថថាខ្លួននិងបំពេញមុខងារ និងតួនាទី ដោយភក្តីភាពនៅមុខងាររបស់ខ្លួន។ ម្យ៉ាងវិញទៀត ការធ្វើសម្បថមិនចាំបាច់ក្នុងការធ្វើឡើងម្តងទៀតនោះទេ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយ។[៧]

## ១.២.ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ស្ថិតនៅក្នុងផ្នែកមួយនៃនគរបាលយុត្តិធម៌បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នៅលក្ខខណ្ឌពិសេសមួយចំនួន ដើម្បីទទួលបានឋានន្តរសក្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ដែលមានបរិយាយដូចខាងក្រោម៖

### ១.២.១.លក្ខខណ្ឌដើម្បីក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌

#### ១.២.១.១.តាមលក្ខខណ្ឌ

ភ្នាក់ងារនគរបាលយុត្តិធម៌សំដៅលើ ៖

ក. នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

ខ. ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ

គ. នាយទាហាន នៃកងរាជអាវុធហត្ថដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

---

[៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦០៧។

[៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦៣។

ឃ. យោធិនផ្សេងៗទៀតនៃកងរាជអាវុធហត្ថ។[៥]

**១.២.១.២.តាមរយៈការធ្វើសម្បថ**

ក្រោយពីទទួលបានមុខងារជាភ្នាក់ងារមន្ត្រីនគរបាយុត្តិធម៌រួចហើយ ភ្នាក់ងារនៃមន្ត្រីនគរបាលយុត្តិធម៌មិនអាចបំពេញមុខងារ ឬតួនាទីរបស់ខ្លួនបានភ្លាមៗនោះទេ ត្រូវឆ្លងកាត់ការធ្វើសម្បថជាមុនសិន។ ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើឡើងនៅសាលាដំបូង។ នៅក្នុងការធ្វើសម្បថជាភ្នាក់ងារនគរបាលយុត្តិធម៌ គឺត្រូវសម្បថថានិង បំពេញមុខងារ ឬតួនាទីរបស់ខ្លួនដោយភាពស្មោះត្រង់។ ដោយករណីពុំចាំបាច់ក្នុងការធ្វើសម្បថគឺ ភ្នាក់ងារនគរបាលយុត្តិធម៌ មិនចាំបាច់ក្នុងការធ្វើសម្បថម្តងទៀតឡើយនៅពេលទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នៅពេលក្រោយ។[៦]

**១.២.២.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចក្នុងការពិនិត្យបទលហុ និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន។ ម្យ៉ាងទៀតភ្នាក់ងារនគរបាលយុត្តិធម៌ ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ដោយធ្វើការប្រមូលព័ត៌មាន ហើយភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើជារបាយការណ៍ ដែលរបាយការណ៍នោះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ ដើម្បីបញ្ជូនទៅមន្ត្រីនគរបាលយុត្តិធម៌។ ដូច្នេះយើងអាចសន្និដ្ឋានបានថាភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកជួយការងារដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ដើម្បីធានាឱ្យកិច្ចដំណើរការនៃការស្វែងរកបទល្មើសប្រព្រឹត្តទៅបានល្អ។

យោងតាមមាត្រា ៧៨ បានចែងថាភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្មដូចជា៖ (១)ពិនិត្យបទល្មើសជាអាទិ៍ បទលហុ។ (២) ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍។ ហើយរបាយការណ៍នេះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ។

## ១.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់ឱ្យមានតួនាទី និងបេសកកម្មបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើល្មើសទៅលើច្បាប់ដូចជាការពិនិត្យ កត់ត្រានៃការប្រព្រឹត្តិ និងធ្វើ

[៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៧៦។

[៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៧៧។

ជារបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ។ មន្ត្រីរាជការ និងភ្នាក់ងារនេះគឺ ស្ថិតក្រោមការគ្រប់គ្រងដោយព្រះរាជអាជ្ញា នៅពេលបំពេញតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងនោះផងដែរ ច្បាប់ដោយឡែកមួយចំនួនអាចផ្តល់នីតិសម្បទា នៅការកំរិតនៃរយៈពេលមួយ និងសមត្ថកិច្ចដោយឡែកមួយចំនួនដល់មន្ត្រីរាជការមួយចំនួនឱ្យក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលយុត្តិធម៌។

**១.៣.១.ការទទួលបាននីតិសម្បទាតាមរយៈច្បាប់ដោយឡែក**

ការទទួលបាននីតិសម្បទាតាមរយៈច្បាប់ដោយឡែកមានចំនួនច្រើន ប៉ុន្តែដោយហេតុថាប្រធានបទរបស់យើងខ្ញុំពុំបានផ្តោតសំខាន់ទៅលើចំណុចនេះខ្លាំងពេកនោះទេ អាស្រ័យហេតុនេះហើយយើងខ្ញុំ បានដកស្រង់ចេញពីច្បាប់ដោយឡែកតែចំណុចមួយចំនួនប៉ុណ្ណោះដែលក្នុងនោះមានដូចជា៖ តាមរយៈច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ តាមរយៈច្បាប់ស្តីពី ព្រៃឈើ តាមរយៈច្បាប់ស្តីពីគយ។

**១.៣.១.១.ការទទួលតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ**

យោងតាមមាត្រា ១០ នៃច្បាប់នេះ មន្ត្រីនៃក្រសួងកិច្ចការនារី បម្រើការងារលើវិស័យ ដែលបញ្ញត្តិដោយច្បាប់ខាងលើ ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**១.៣.១.២.តាមរយៈច្បាប់ស្តីពីព្រៃឈើ**

ដោយយោងតាមមាត្រា ៧៦ និងមាត្រា៧៧ នៃច្បាប់នេះ មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺសំដៅទៅលើមន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌មានន័យថា ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើស ព្រៃឈើ និងចងក្រងសំណុំរឿងជូនទៅតុលាការ។ មន្ត្រីរដ្ឋបាលព្រៃឈើធ្វើសច្ចាប្រណិធាន បំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តឱ្យស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**១.៣.១.៣.តាមរយៈច្បាប់ស្តីពីគយ**

យើងបានដឹងហើយថាចំពោះមន្ត្រីគយ ក៏អាចទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ផងដែរ។ មន្ត្រីគយ ដែលបានសច្ចាប្រណិធាន អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន គឺលុះត្រាតែសាមីខ្លួនបានទទួល នីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ចំពោះមន្ត្រីគយដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសគយតាមដែនសមត្ថកិច្ចរបស់ខ្លួន។ នៅ

ពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ មន្ត្រីគយត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ពាក់ឋានន្តរសក្តិ លើកលែងតែមានការណែនាំ ដោយឡែក ពីនាយកទីចាត់ការគយ និងរដ្ឋាករ។ សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិ របស់មន្ត្រីគយត្រូវកំណត់ដោយអនុក្រឹត្យ។

**១.៣.២.សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត**

នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ បានចេញប្រកាសរួម តែងតាំងខ្លួនរួចហើយ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ មិនទាន់អាចទៅបំពេញ មុខងារនេះបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងកាត់ដំណាក់កាលមួយផ្សេងទៀត ដូចមន្ត្រីនគរបាល យុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ដែលដំណាក់កាលនេះគេឱ្យឈ្មោះថា ការធ្វើសម្បថ។

**១.៣.២.១.ទីកន្លែងដែលត្រូវធ្វើសម្បថ**

យោងតាមមាត្រា៨២ ត្រង់វាក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមន្ត្រីរាជការ និងភ្នាក់ងារ សាធារណៈដទៃទៀតអាចមកបំពេញមុខងារបានទាល់តែឆ្លងកាត់នូវសម្បថជាមុនសិន។ ប៉ុន្តែ សម្បថរបស់គាត់ មិនធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ ដូចមន្ត្រីនគរបាលយុត្តិធម៌នោះទេគឺគាត់ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ច តាមខេត្ត រាជធានី នីមួយៗ ដូចគ្នានឹងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ។[១០]

**១.៣.២.២.នត្តិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត**

នត្តិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺ មានភាពខុសគ្នាពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ព្រោះសម្បថរបស់មន្ត្រីរាជ ការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺនត្ថិភាពចំពោះអញ្ញត្រកម្ម មានន័យថា បើយោងតាម មាត្រាខាង គឺមិនមានកំណត់នូវករណីលើកលែងចំពោះសម្បថឡើយ នៅពេលដែលបានទទួលនូវ គុណសម្បត្តិរួចរាល់នោះ ។ ចំណុចនេះហើយដែលខ្ញុំមើលឃើញថាខុសគ្នាមន្ត្រីនគរបាលយុត្តិធម៌ក៏ ដូចជាភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ព្រោះពួកគេមានករណីលើកលែងមួយចំពោះសម្បថរបស់ខ្លួន ដូចបានរៀបរាប់ខាងដើមហើយថា "សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយនៅពេលដែលទទួល បាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬ នៅពេលដែលទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរ បាលយុត្តិធម៌នាពេលក្រោយទៀត"។ ផ្ទុយទៅវិញចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទ ទៀតទាំងនេះពុំមានចែងច្បាស់លាស់អំពីចំណុចនេះឡើយ។

[១០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨២។

## ផ្នែកទី ២ ៖ តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌

តួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានកំណត់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃក្របខ័ណ្ឌដែលមានជាការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង និងការស៊ើបអង្កេតតាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ។

### ២.១.ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង

ក្នុងនីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងមានច្រើនចំណុចដែលយើងនឹងធ្វើការបកស្រាយ ប៉ុន្តែមុននឹងធ្វើការបកស្រាយឱ្យបានលម្អិតអំពីនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង យើងនឹងធ្វើការបកស្រាយអំពីនិយមន័យនៃបទល្មើសជាក់ស្តែងជាមុនសិន។ ដែលក្នុងនោះផងដែរ បទល្មើសជាក់ស្តែង គឺជាបទល្មើសដែលកំពុងប្រព្រឹត្ត ឬជាបទល្មើសដែលទើបប្រព្រឹត្តរួចភ្លាមៗ។ ត្រូវបានចាត់ទុកជាបទល្មើសជាក់ស្តែងផងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជន ស្រែកដេញចាប់ ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស (មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )។[១១]

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេត គឺជាភាពបន្ទាន់ដែលតម្រូវឱ្យមានការប្រមូលនូវភស្តុតាងបទល្មើសដែលនៅមាននៅឡើយដែលវាទើបតែបានប្រព្រឹត្តថ្មីៗ។ ដើម្បីឆ្លើយតបភាពរហ័សភាពចាំបាច់នៃកិច្ចស៊ើបទើបក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបង្កើតនូវវិធានដែលរហ័ស និងបង្កើតអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌។

ការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាដំណាក់កាលដែលពុំអាចឱ្យវេលាណាមួយត្រូវបានបាត់បង់ឡើយ។ ការយឺតយ៉ាវបន្តិចបន្តួចជាមូលហេតុនៃការបាត់បង់នូវតម្រុយនៃពិរុទ្ធភាព ឬពិរុទ្ធជននិងស្លាកស្នាមនៃបទល្មើស។

#### ២.១.១.ការចុះទៅកាន់ទីកន្លែងកើតហេតុ

ការចុះទៅកាន់ទីកន្លែងកើតហេតុ គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ភ្លាមៗជូនព្រះរាជអាជ្ញា។ ហើយមន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់កន្លែងកើតហេតុដើម្បីធ្វើការពិនិត្យ និងស្រាវជ្រាវកំណត់មុខសញ្ញាបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធានារក្សា ឬការពារនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែង

[១១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨៦។

បទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនបាន គឺដើម្បីរក្សាសមាសភាពដើមនៅកន្លែងកើតហេតុ ព្រោះបុគ្គលខ្លះគាត់អាចនឹងមានការពាក់ពន្ធ ឬអាចផ្តល់ជាព័ត៌មានជាក់លាក់ណាមួយអំពីព្រឹត្តិការណ៍ទាំងនោះ ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។ ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ត្រង់ចំណុចនេះមានន័យថាបើរឿងហេតុនោះមានតម្រុយច្បាស់លាស់ហើយកំណត់មុខសញ្ញាបានហើយ តែមន្ត្រីនគរបាលយុត្តិធម៌មិនអាចចាត់ការបាននោះ ដូច្នេះត្រូវការព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេតផ្ទាល់តែម្តង។ ប្រសិនមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូល នៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ច ដែនដី)។[១២]

### ២.១.២.ការឃាត់ខ្លួន

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត (មាត្រា ៨៧)។[១៣]"មន្ត្រីនគរបាលយុត្តិធម៌"អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស និងបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុ ក្នុងករណីខាងក្រោយនេះ ការឃាត់ខ្លួនអាចធ្វើទៅបានលុះត្រាតែបុគ្គលនោះប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។[១៤] នៅពេលមានការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូន ព្រះរាជអាជ្ញាភ្លាម។ រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ការពន្យារពេលនៃការឃាត់ខ្លួនចំនួន ២៤ ម៉ោងទៀតអាចធ្វើទៅបានលុះត្រាតែមានលក្ខខណ្ឌដូចតទៅ៖

- មានតម្រុយបង្ហាញឱ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនជានីតិជន ក្នុងបទឧក្រិដ្ឋ។
- ការពន្យារពេលជាវិធានការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។
- ការអនុញ្ញាតដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ចំពោះអនីតិជនការឃាត់ខ្លួនត្រូវបានបែងចែកជា ៣ ប្រភេទតាមអាយុរបស់អនីតិជនដែលត្រូវឃាត់ខ្លួន ៖

- ចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំ មិនអាចឃាត់ខ្លួនបានឡើយ។

[១២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៩។

[១៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨៧។

[១៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៦។

- ចំពោះអនីតិជនដែលមានអាយុ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដែលត្រូវជាប់សង្ស័យប្រព្រឹត្ត បទឧក្រិដ្ឋ មិនអាចឃាត់ខ្លួនហួសពីរយៈពេល ៣៦ម៉ោង បានឡើយ។
- ចំពោះអនីតិជនដែលមានអាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលត្រូវជាប់សង្ស័យប្រព្រឹត្ត បទឧក្រិដ្ឋ មិនអាចឃាត់ខ្លួនហួសពីរយៈពេល ៤៨ម៉ោង បានឡើយ។
- ចំពោះអនីតិជនដែលមានអាយុ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដែលត្រូវជាប់សង្ស័យប្រព្រឹត្ត បទមជ្ឈិម មិនអាចឃាត់ខ្លួនហួសពីរយៈពេល ២៤ម៉ោង បានឡើយ។
- ចំពោះអនីតិជនដែលមានអាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលត្រូវជាប់សង្ស័យប្រព្រឹត្ត បទមជ្ឈិម មិនអាចឃាត់ខ្លួនហួសពីរយៈពេល ៣៦ម៉ោង បានឡើយ។

**២.១.៣.ការឆែកឆេរ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងធ្វើការចាប់យកវត្ថុតាងនៅក្នុងលក្ខខណ្ឌដែលចែងនៅក្នុងមាត្រា៩១នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[១៥] ការឆែកឆេរ ក្នុងការស៊ើបអង្កេតជាក់ស្តែងមានគោលបំណងក្នុងការស្វែងរកជនល្មើសដែលបានធ្វើការគេចខ្លួននៅក្នុងលំនៅដ្ឋាននៃបុគ្គលណាម្នាក់ ឬនៅទីកន្លែងណាមួយហើយ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ នៅលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ឬទីកន្លែងណាមួយ ដើម្បីក្នុងស្វែងរកជនល្មើស និងវត្ថុតាង ឧបករណ៍ អាវុធ សម្ភារៈផ្សេងៗដែលទុកប្រើក្នុងការប្រព្រឹត្តបទល្មើស។ ក្នុងករណីខាងលើនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានការសុំអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ហើយក្នុងការសុំអនុញ្ញាតត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការឆែកឆេរនៅចំពោះអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីនេះត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ហើយសាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនេះទេ។ ក្នុងករណីការឆែកឆេរនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចាប់ផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយលើកលែងតែក្នុងករណីមួយចំនួនដូចខាងក្រោម៖

- ក្នុងករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីដែលចែងក្នុងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីដែលមានសម្រែកឱ្យគេជួយពីក្នុងទីកន្លែង

[១៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨១។

- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីឆែរឆេរនៅគ្រប់ទីកន្លែងដែលផលិតផល រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់ គ្រឿងញៀន។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ ៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីម្នាក់ៗ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមីៗ មួយវិញទៀតមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាស សារព័ត៌មានសោតទស្សន៍ បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យមានការយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។[១៦]

### ២.១.៤.ការចាប់យកវត្ថុតាង

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរ ហើយបានរកឃើញនូវវត្ថុណាមួយដែលគួរឱ្យសង្ស័យគាត់មានសិទ្ធអំណាចចាប់យកនៅវត្ថុតាងនោះបាន។ ក្រោយពេលដែលគាត់បានចាប់យកវត្ថុតាងនោះមកហើយ គាត់ត្រូវបង្ហាញអ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់ថាគាត់បានចាប់បានភស្តុតាងនេះហើយគាត់បានចាប់យកទៅវេចខ្ចប់ដោយមានបិទស្លាក និងបោះត្រាដើម្បីរក្សាទុកមិនឱ្យមានការលួចដូរនោះឡើយ។ មិនត្រឹមតែប៉ុណ្ណោះនៅពេលដែលបញ្ចប់ប្រតិបត្តិការណ៍របស់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកវត្ថុតាងដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលបានចាប់យក ហើយត្រូវភ្ជាប់ជាមួយនឹងកំណត់ហេតុនៃការឆែកឆេរមួយទៀត ដែលកំណត់ហេតុនៃការឆែកឆេរនោះត្រូវកំណត់ឱ្យបានច្បាស់លាស់ពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់ផ្តល់ការអនុញ្ញាតឱ្យ ហើយការអនុញ្ញាតនោះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកចូលរួម ត្រង់ចំណុចនេះគឺចង់សំដៅជាពិសេសទៅដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី២ (ពីរ) រូបដែលមានវត្តមានហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬផ្តិតម្រាមដៃ។

[១៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩១។

ព្រះរាជអាជ្ញាមានសមត្ថកិច្ច អាចបង្គាប់ឱ្យប្រគល់នូវវត្ថុដែលចាប់បាន ជូនទៅម្ចាស់ដើមវិញ ប្រសិនបើយល់ឃើញថាវត្ថុនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតនោះទេ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ហើយវត្ថុនោះពុំមែនជាវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិទេ ត្រូវធ្វើការប្រគល់ជូនម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខណ្ឌនៃការស៊ើបអង្កេត។ ប្រសិនបើព្រះរាជអាជ្ញាពុំព្រមប្រគល់ឱ្យវិញទេ អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាសុំឱ្យប្រគល់វត្ថុដែលចាប់យកនោះបាន។

**២.១.៥.ការស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការកោះហៅបុគ្គលគ្រប់រូបរួមទាំងជនសង្ស័យ ថាបានចូលរួមប្រព្រឹត្តបទល្មើសមកអង្គភាពរបស់ខ្លួន ដើម្បីធ្វើការសាកសួរ ឬធ្វើការស្តាប់ចម្លើយជនទាំងនោះនូវព័ត៌មានចាំបាច់ និងសំខាន់ៗដែលពួកគេបានដឹង (មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។[១៧]គ្រប់ការស្តាប់ចម្លើយនីមួយៗ ត្រូវមានកំណត់ហេតុ ហើយកំណត់ហេតុនេះត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ និងដើម្បីឱ្យព្រះរាជអាជ្ញា ឬចៅក្រមធ្វើការពិនិត្យនូវនីត្យានុកូលភាព និងនិយ័តភាពនៃការស្តាប់ចម្លើយនេះ។ ក្នុងករណីការស៊ើបអង្កេតជាក់ស្តែងដែលត្រូវការការកោះហៅសាក្សី ដើម្បីមកបញ្ជាក់ពីអង្គហេតុ ឬចម្លើយឱ្យបានច្បាស់ដោយមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែប្រសិនបើសាកសាក្សីមិនរួមដៃ ឬមានភាពរឹងទទឹងសាក្សីអាចត្រូវបង្ខំតាមរយៈសេចក្តីបង្គាប់ឱ្យចូលខ្លួនដែលចេញដោយព្រះរាជអាជ្ញាតាមសំណើររបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយមន្ត្រីនគរបាលយុត្តិធម៌និងត្រូវទទួលការអនុញ្ញាតឱ្យប្រើកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន។ ផ្ទុយទៅវិញប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌មិនបានគោរពតាមវិធានការនៃ (មាត្រា ១០៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ) នោះទេ រាល់កំណត់ហេតុ នៃការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ និងត្រូវចាត់ទុកជាមោឃៈ។[១៨]

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍ របស់បុគ្គលដែលផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលត្រូវស្បថថា និយាយកាពិតស្របតាមជំនឿ ឬសាសនាដែលខ្លួនកាន់។ សម្រាប់អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមអ្នកស៊ើបអង្កេត (កងរាជអាវុធហត្ថ ឬនគរបាលយុត្តិ) ឬក្នុងចំណោមបុគ្គលដែលពាក់ពន្ធក្នុងរឿងក្តីជាមួយគ្នានេះឡើយ។ នៅក្នុងទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីដែលចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអាននូវខ្លឹមសារនៃកំណត់ហេតុនោះដោយប្រើសម្លេងខ្លាំងៗ ហើយមន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែបាន។

[១៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៤។

[១៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០៩។

កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃទេមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[១៩]

### ២.១.៦.ការត្រួតពិនិត្យខាងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការត្រួតពិនិត្យខាងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្រ្តមិនអាច ក្នុងការបង្អង់បាន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្វែងរក និងស្នើសុំអ្នកដែលជំនាញក្នុងការធ្វើត្រួតពិនិត្យខាងផ្នែកបច្ចេកទេស និងវិទ្យាសាស្រ្តទៅលើភស្តុតាងដែលគាត់ទទួលបាននោះ ដើម្បីឱ្យគាត់ស្វែងរកភស្តុតាងបន្តទៀត។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចដែលបានចែងក្នុងមាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) បុគ្គលនេះត្រូវសច្ចាតាមសាសនា ឬជំនឿដែលខ្លួនបានកាន់ និងត្រូវធ្វើការស្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ហើយអ្នកដែលស្បថត្រូវស្បថថានឹងធ្វើការជួយដោយភក្តីភាពដល់តុលាការ។[២០]

### ២.១.៧.ការបញ្ជូនកំណត់ហេតុវត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា (មាត្រា ១០៧) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[២១] ប្រសិនបើមានបុគ្គលឃាត់ខ្លួន នៅពេលផុតកំណត់រយៈពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌សុំសេចក្តីសម្រេចពីព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនខ្លួនជននេះទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាពឡើងវិញដែលបានចែងក្នុង (មាត្រា ១០៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[២២] ប្រសិនបើព្រះរាជអាជ្ញាសម្រេចថាឱ្យបញ្ជូន មន្ត្រីនគរបាលយុត្តិធម៌នឹងបញ្ជូនខ្លួនបុគ្គលនោះទៅព្រះរាជអាជ្ញា ក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ ប្រសិនបើមានការលំបាក ក្នុងការដឹកជញ្ជូន ឬចម្ងាយនៃការដឹកជញ្ជូន រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញា (មាត្រា ១០៤ កថាខណ្ឌទី២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[២៣]

## ២.២.ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង

ការស៊ើបអង្កេតបទល្មើសបឋម គឺជាការស៊ើបអង្កេតមួយដែលជាទូទៅគេប្រើប្រាស់សម្រាប់ធ្វើការស៊ើបអង្កេតក្នុងករណីដែលមានបទល្មើសមិនជាក់ស្តែង។ ហើយការបើកការស៊ើបអង្កេតបទល្មើសបឋមនេះ

[១៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៣។

[២០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៥។

[២១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០៧។

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០៣។

[២៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០៤។

ទៀតសោធអាចដំណើរការបានដូចមានចែងក្នុងមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌថា"កាលណាបានដឹងអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបទល្មើសបឋមដោយខ្លួនឯងឬតាមការសុំរបស់ព្រះរាជអាជ្ញា។[២៤]

### ២.២.១. វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសមិនជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបានផងដែរ ក្នុងករណីវិធានស៊ើបអង្កេតមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានការយល់ព្រមដែលធ្វើឡើងដោយលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរនោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែង នោះមិនចេះអក្សរហើយយល់ព្រមឱ្យឆែកឆេរ។

ហើយក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធមិនឱ្យធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចធ្វើសំណើសុំដីកាអនុញ្ញាតឱ្យធ្វើ ការឆែកឆេរដែលចេញដោយប្រធានសាលាដំបូង ហើយការដឹកនាំនៃវិធានក្នុងការឆែកឆេរនេះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា។ ការឆែកឆេរនេះត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីពុំអាចយកមន្ត្រីនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

ចំពោះការឆែកឆេរនេះ មិនផ្តើមការឆែកឆេរនៅមុខម៉ោង ០៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ (មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់ (វត្ថុតាង) យកនោះ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញ អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួចធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងក្តីនេះបាន។ ការស្តាប់ចម្លើយ សួរយក

[២៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ឧសីហា ២០០៧, មាត្រា១១១។

ចម្លើយ ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីដែលជនត្រូវបានសួរចម្លើយជាជនបរទេស គថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីសួរចម្លើយរួចហើយ ត្រូវអានដោយសម្លេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានសួរចម្លើយ និងអ្នកបកប្រែបើមាន ហើយឱ្យចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយក្នុងករណីដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតម្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុ អំពីហេតុការណ៍នេះ (មាត្រា ១១៤ និងមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅនេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឱ្យចេញ ដីកាបញ្ជាឱ្យចូលខ្លួនដែលដីកានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួនបាន (មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ២.២.២. វិធានការក្នុងការឃាត់ខ្លួន និងបញ្ជូនខ្លួនជនដែលត្រូវបានឃាត់ខ្លួន

ការឃាត់ខ្លួនជនជាប់សង្ស័យយោងតាមមាត្រា ១១៦ បញ្ញត្តិថា "កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួន នៃមាតិកាទី២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគភ៌ទី ៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ត្រូវយកមកអនុវត្តដូចគ្នា ហេតុនេះអត្ថន័យដែលបានបកស្រាយយ៉ាងលម្អិតរួចហើយដូចមានក្នុងការស៊ើបអង្កេតករណីជាក់ស្តែងខាងលើត្រូវយកមកពិភាក្សា ឬធ្វើការសិក្សាដូចគ្នាទាក់ទងនឹងការឃាត់ខ្លួនជនជាប់សង្ស័យក្នុងការស៊ើបអង្កេតបឋម។

### ២.២.៣.កំណត់ហេតុក្នុងការស្តាប់ចម្លើយ

រាល់ការស្តាប់ចម្លើយទាំងឡាយ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវតែគោរពឱ្យបានត្រឹមត្រូវតាមមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពី (កំណត់ហេតុស្រង់យកចម្លើយនៅក្នុងការស៊ើបអង្កេតបឋម) និងមាត្រា ១១៥ បានចែងថា "ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ហើយកំណត់ហេតុត្រូវដកស្រង់ដោយ ត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែ ដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ។

## ២.៣.ការស៊ើបអង្កេតតាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ

ក្រោយពីបានសិក្សាអំពីសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេតជាក់ស្តែងក៏ដូចជាការស៊ើបអង្កេតបឋមរួចមក នោះយើងនឹងសិក្សាបន្តនៅក្នុងដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌អំពីដីកាចាត់ឱ្យស៊ើបសួរជំនួស។

### ២.៣.១.និយមន័យ

ដីកាចាត់ឱ្យស៊ើបសួរជំនួស គឺជាការធ្វើប្រតិភូកម្មមួយផ្នែកនៃអំណាចរបស់ចៅក្រមស៊ើបសួរ ដោយហេតុថាចៅក្រមស៊ើបសួរមិនអាចបំពេញតួនាទីតែម្នាក់ឯងរហូតនូវរាល់កិច្ចចាំបាច់ ដើម្បីដឹកនាំការស៊ើបសួរឱ្យបានល្អនោះឡើយ ព្រោះជួនកាលត្រូវជួបប្រទះនូវការលំបាកផ្នែកសម្ភារៈ (ត្រូវធ្វើការឆែកឆេរព្រមៗគ្នានៅកន្លែងជាច្រើន ដើម្បីឱ្យមានប្រសិទ្ធិភាពត្រូវបំពេញភារកិច្ចនៅតាមសមត្ថកិច្ចដែនដីឆ្ងាយៗពីគ្នា) ពីព្រោះថាមានការស្រាវជ្រាវជាច្រើនដែលត្រូវដឹកនាំ ហើយពុំមានពេលវេលា និងមធ្យោបាយធ្វើតែម្នាក់ឯងបានឡើយ។[២៥]ដីកាចាត់ឱ្យស៊ើបសួរជំនួសនេះមិនមានលក្ខណៈទូទៅនោះទេគឺត្រូវមានការណែនាំឱ្យបានច្បាស់លាស់ ដោយដីកាចាត់ឱ្យស៊ើបសួរជំនួសនេះចៅក្រមស៊ើបសួរត្រូវ៖

- បញ្ជាក់ប្រភេទនៃកិច្ចការដែលត្រូវធ្វើ ហើយកិច្ចការនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់
- កំណត់ថេរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស
- ត្រូវមានចុះការបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានការបោះត្រាផងដែរ។

ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសនេះទៀតសោធ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យជំនួសបានគ្រប់ពេលវេលា។[២៦]

### ២.៣.២.លក្ខណៈទូទៅ

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់អំណាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចស៊ើបសួរដូចមានកំណត់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយមិនអាចស៊ើបសួរលើសពីអ្វីដែលបានកំណត់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះទេ ត្រង់ចំណុចនេះមានន័យថាចៅក្រមស៊ើបសួរទទួលបានអំណាចដឹកនាំមន្ត្រីនគរបាលយុត្តិធម៌តាមដីកាចាត់ឱ្យស៊ើបសួរជំនួស។ ផ្ទុយទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ឬការស៊ើបអង្កេតបឋមដែលនគរបាលយុត្តិធម៌ប្រើប្រាស់នូវ អំណាចដែលប្រគល់ឱ្យខ្លួនដោយមាត្រា ៨៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬមាត្រា ១១១ និងមាត្រាបន្ត

[២៥] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល ឆ្នាំ ២០០៩។

[២៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៧៤។

បន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬអនុវត្តតាមសេចក្តីណែនាំ។ ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ អំណាចដែលត្រូវបានផ្ទេរឱ្យនគរបាលយុត្តិធម៌ គឺមានកម្រិត ដោយអនុវត្តទៅតាមមាត្រា ១៧៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ របៀបស៊ើបអង្កេតនេះមានលក្ខណៈពិសេស ដូច្នេះគេមិនអាចធ្វើការស្រាវជ្រាវ ក្នុងពេលតែមួយលើរឿងហេតុតែមួយ តាមរបៀបស៊ើបអង្កេតផ្សេងទៀតឡើយ (ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬការស៊ើបអង្កេតបទល្មើសបឋម)។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទបានឡើយ (មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ២.៣.៣.កិច្ចអនុវត្តនានា

មន្ត្រីនគរបាលយុត្តិធម៌បំពេញត្រឹមតែកិច្ច ដែលមានចុះក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសដែលជាដីកាមួយពិសេស (ដែលបញ្ញត្តិកិច្ចមួយ ឬច្រើន)។

ចំណែកលក្ខណៈពិសេសនៃកិច្ចការរបស់នគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនេះ មានដូចខាងក្រោម៖

- **ការទទួលបណ្តឹង**

ការទទួលបណ្តឹងខុសប្លែកពីការស៊ើបអង្កេតបទល្មើសជាក់ស្តែងឬការស៊ើបអង្កេតបឋម។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹង អាចសរសេរកំណត់ហេតុទទួលដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយចម្លងទម្រង់នៃដីកានោះ និងបេសកកម្ម។

- **ការឃាត់ខ្លួន**

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវសិទ្ធិអំណាចក្នុងការឃាត់ខ្លួនជនត្រូវចោទ។ ជាក់ស្តែង នៅក្នុងអំឡុងពេលចុះប្រតិបត្តិការស៊ើបសួរ តាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គល ដែលខ្លួនសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស។ លើសពីនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួន បុគ្គលដែលខ្លួនយល់ឃើញថា អាចផ្តល់ព័ត៌មាន ដែលមានជាប់ពាក់ព័ន្ធនឹងរឿងហេតុដែលបានកើតឡើងបានផងដែរ ក្នុងករណីដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីចៅក្រមស៊ើបសួរ។[២៧]

រាល់ពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើនូវកិច្ចសំខាន់ចំនួន ៣ ទាក់ទងនឹងកំណត់ហេតុដែលមានដូចជា ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ការចុះ

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៦ កថាខណ្ឌ១។

ការឃាត់ខ្លួនក្នុងបញ្ជីនៃការឃាត់ខ្លួន និងការធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ កិច្ចទាំងអស់នេះត្រូវបំពេញទៅតាមដំណាក់កាលនីមួយៗ ដែលមានន័យថានៅរាល់ពេលមន្ត្រីនគរបាលយុត្តិធម៌ធ្វើ ការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ កំណត់ហេតុស្តីពីការឃាត់ខ្លួនបុគ្គលនោះ។[២៨] ទន្ទឹមនឹងនេះគ្រប់ការឃាត់ខ្លួនត្រូវធ្វើការចុះនៅក្នុងបញ្ជីស្តីពីការឃាត់ខ្លួន ដើម្បីទទួលជនដែលត្រូវឃាត់ខ្លួន ដោយត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ដើម្បីរក្សាទុកសម្រាប់ជូនទៅអាជ្ញាធរតុលាការ ក្នុងករណីដែលត្រូវការ។ ជាមួយគ្នានោះដែរមន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវធ្វើកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួនផងដែរ ដើម្បីភ្ជាប់ជាមួយនឹងសំណុំរឿង។

- **សិទ្ធិអំណាចក្នុងការស្តាប់ចម្លើយសាក្សី**

មន្ត្រីនគរបាលយុត្តិធម៌អាចក្នុងការស្តាប់ចម្លើយពីសាក្សីបាន។ មុននឹងធ្វើការស្តាប់ចម្លើយ សាក្សីត្រូវធ្វើការសម្បថតាមសាសនា ឬជំនឿរបស់ខ្លួនជាមុនសិន។ ប៉ុន្តែសម្រាប់សាក្សី ដែលមិនចាំបាច់ក្នុងការធ្វើសម្បថដូចដែលមានរៀបរាប់នៃមាត្រា ១៥៦ (សាក្សីដែលអាចអនុញ្ញាតឱ្យរួចផុតពីសម្បថ) គឺមិនចាំបាច់ធ្វើការស្បថនោះទេ។ បើក្នុងករណីដែលការស្តាប់ចម្លើយ បានបង្ហាញសកម្មភាពដែលបាន លេញចេញនៅពិរុទ្ធភាព មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការប្រឆាំង ឬត្រូវធ្វើការបញ្ចប់ការស្តាប់ចម្លើយភ្លាម ហើយបញ្ជូនដំណឹងនេះទៅចៅក្រមស៊ើបសួរភ្លាម។ ក្នុងករណីដែលសាក្សីមិនចេះភាសាខ្មែរ នោះមន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែ ហើយអ្នកបកប្រែត្រូវធ្វើការសម្បថទៅនឹងសាសនា ឬជំនឿរបស់ខ្លួន និងធ្វើឡើងនៅចំពោះមុខតុលាការ ដោយត្រូវស្បថថាខ្លួនគាត់ត្រូវចូលខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវជូនតុលាការ។ ក្នុងករណីដែលសាក្សីមិនព្រមចូលបង្ហាញខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរ ក្នុងករណីនេះដែលចៅក្រមស៊ើបសួរអាចបញ្ជាឱ្យចូលខ្លួនដែលមានចុះអត្តសញ្ញាណនៃសាក្សី។ ប្រសិនបើសាក្សីនៅតែមិនព្រម ចូលតាមបញ្ជានោះមន្ត្រីនគរបាលយុត្តិធម៌ និងប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ហាញនៅចំពោះមុខ។ ពុំនោះទេអាចត្រូវបានបង្ខំតាមមាត្រា ១៧៩ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ការចេញបញ្ជាបង្គាប់ឱ្យចូលខ្លួនដោយចៅក្រមស៊ើបសួរ ក្រោយពីទទួលដំណឹងពីមន្ត្រីនគរបាលយុត្តិធម៌។[២៩]

- **ការឆែកឆេរ និងការរឹបអូស**

ក្នុងករណីដែលមានការឆែកឆេរត្រូវប្រព្រឹត្តទៅដោយមន្ត្រីនគរបាលយុត្តិធម៌។ ហើយមន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវសិទ្ធិអំណាចក្នុងការឆែកឆេរ និងការរឹបអូសបានតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ជាបឋមនូវការអនុញ្ញាតពីសំណាក់ចៅក្រមស៊ើបសួរ ការឆែកឆេរត្រូវធ្វើឡើងនៅចំពោះមុខអ្នកកាន់កាប់ទី កន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើនៅចំពោះមុខ សាក្សី ២ (ពីរ) នាក់ដែលត្រូវបានចាត់តាំង ដោយមន្ត្រី

---

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៧។

[២៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩៣។

នគរបាលយុត្តិធម៌។ សាក្សីដែលត្រូវបានចាត់តាំងនោះមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ការឆែកឆេរមិនអាច ប្រព្រឹត្តទៅនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយលើកលែងតែករណីពិសេស ដែលមានកំណត់ដោយច្បាប់ប៉ុណ្ណោះ។ ហើយការឆែកឆេរអាចធ្វើឡើងគ្រប់ទីកន្លែងដែលអាចឱ្យគេរកឃើញវត្ថុមានប្រយោជន៍ដល់ការបង្ហាញការពិត លើកលែងតែទីកន្លែងឆែកឆេរមានការដាក់កម្រិតដែលទាក់ទងជាពិសេសចំពោះសភា កន្លែងការទូត ការិយាល័យមេធាវី និងសហគ្រាសសារព័ត៌មានលើវត្ថុ និងឯកសារដែលមានប្រយោជន៍ត្រូវចុះបញ្ជីសារពើភ័ណ្ឌ និងបិទស្លាកបោះត្រាភ្លាម។

- **ការស្តាប់តាមទូរស័ព្ទ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ដូចជា សារតាមទូរស័ព្ទ ឬសារតាមអិនធើណែត បានផងដែរ កាលណាកិច្ចនេះត្រូវបានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស។[៣០] កាលណាស្តាប់រួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលការតែងតាំងតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសនោះត្រូវធ្វើការចម្លងសម្លេងដែលថតបាននោះ ទៅ ជាលាយលក្ខណ៍អក្សរ ដោយត្រូវសរសេរឱ្យបានត្រឹមត្រូវទៅតាមខ្លឹមសារទាំងស្រុងនៃសម្លេងដែលថតបាននោះ ឱ្យទៅចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានសិទ្ធិអំណាចសន្និដ្ឋានការស៊ើបសួរជាសត្យានុម័តបាននោះទេ ដោយហេតុថាមាន ចៅក្រមស៊ើបសួរប៉ុណ្ណោះដែលមានសិទ្ធិផ្តួចផ្តើមធ្វើសេចក្តីសន្និដ្ឋានក្រោមលក្ខខណ្ឌចែងយ៉ាងច្បាស់លាស់ដោយអត្ថបទច្បាប់។

- **សេចក្តីសន្និដ្ឋានស៊ើបសួរ**

សេចក្តីសន្និដ្ឋានស៊ើបសួរត្រូវចុះឱ្យច្បាស់លាស់ក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស (សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ឬសេចក្តីសន្និដ្ឋានបែបបច្ចេកទេស)។

---

[៣០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៨៣។

# ជំពូកទី២

# បញ្ហាប្រឈម និងដំណោះស្រាយ
# របស់មន្ត្រីនគរបាលយុត្តិធម៌
# ក្នុងការស៊ើបអង្កេត

# ជំពូកទី២

# បញ្ហាប្រឈម និងដំណោះស្រាយ របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត

មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីជាជំនួយការរបស់តុលាការ និងមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យលើបទល្មើស បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងដែលមានចែងក្នុងមាត្រា ៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងនោះផងដែរ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងការចុះស៊ើបអង្កេត លើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបទល្មើសបឋម ហើយនៅក្នុងការស៊ើបអង្កេតនេះ មន្ត្រីនគរបាលយុត្តិធម៌អាចជួបនៅបញ្ហាប្រឈមផ្សេងៗក្នុងការចុះអនុវត្តតួនាទី ឬបំពេញបេសកកម្ម។ ក្នុងជំពូកនេះយើងនឹងធ្វើការលើកឡើងអំពីបញ្ហាប្រឈម និងដំណោះស្រាយរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

## ផ្នែកទី ១៖ បញ្ហាប្រឈមក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

ដូចដែលបានលើកឡើងខាងលើនៅក្នុងការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌រមែងជួបនៅបញ្ហាប្រឈមផ្សេងៗ។ ហើយនៅក្នុងចំណុចនេះផងដែរយើងខ្ញុំនឹងធ្វើការលើកបង្ហាញអំពីបញ្ហាប្រឈមមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌អាចជួបប្រទះដូចជា៖ កង្វះខាតភស្តុតាងក្នុងការស៊ើបអង្កេត កត្តាមធ្យោបាយក្នុងការស៊ើបអង្កេត និងកង្វះខាតធនធានរបស់មន្ត្រីនគរបាលយុត្តិធម៌។

### ១.១. កង្វះខាតភស្តុតាងក្នុងការស៊ើបអង្កេត

ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងពីហេតុការណ៍តាមរយៈ មធ្យោបាយដោយខ្លួនផ្ទាល់ ឬតាមរយៈពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្តី នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតួនាទីក្នុងការស៊ើបអង្កេត និងស្វែងរកភស្តុតាង ដើម្បីកំណត់នូវបទល្មើសដែលបានកើតមានឡើង។ បន្ទាប់មកមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការកំណត់ប្រភេទនៃបទល្មើសថាបទល្មើសដែលកើតឡើងជាបទល្មើសជាក់ស្តែង ឬជាបទល្មើសបឋមជាមុនសិន។ ហើយបើករណីនោះជាបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការចុះទៅកន្លែងកើតហេតុភ្លាមៗ និងធ្វើការស្វែងរកភស្តុតាង សម្រាប់ក្នុងការកំណត់អត្តសញ្ញាណរបស់ជនល្មើស។ ប៉ុន្តែក្នុងករណីខ្លះមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវកំណត់ចំណាត់ថ្នាក់នៃបទល្មើស តែជនល្មើសបានបំផ្លាញភស្តុតាងមួយចំនួន ដែលធ្វើឱ្យមានការបាត់បង់ភស្តុតាងសំខាន់ៗផងដែរ។ ហើយករណីនេះដែរអាចនឹងមានការលំបាកដល់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការកំណត់អត្តសញ្ញាណរបស់ជនល្មើស និងមិនអាចកំណត់ចំណាត់ថ្នាក់នៃបទល្មើសបាន។

**១.១.១.សាក្សីមិនសហការ ឬមិនមានសាក្សីដែលបានឃើញហេតុការណ៍**

ក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាការកំណត់អត្តសញ្ញាណរបស់ជនល្មើស គឺអាចកំណត់បានតាមរយៈសកម្មភាពជាក់ស្តែង វត្ថុតាង ឬភស្តុតាង ដែលក្នុងនោះមានភស្តុតាងជាសាក្សី ឬភស្តុតាងជាវត្ថុតាងដែលជនល្មើសបានបន្សល់ទុកនៅស្លាកស្នាម។ ក្នុងចំណុចនេះយើងនឹងធ្វើការលើកបង្ហាញអំពីការមិនសហការរបស់សាក្សីដែលបានឃើញ ហេតុការណ៍នៅពេលដែលជនល្មើសបានប្រព្រឹត្ត ប៉ុន្តែសាក្សីបែរជាធ្វើការបដិសេធថាមិនបានដឹង ឮនៅហេតុការណ៍ដែលបានកើតឡើងរួចនោះទៅវិញ។ ហើយចំពោះបញ្ហាប្រឈម ដែលមិនអាចស្វែងរកសាក្សីដែលពាក់ព័ន្ធនៅក្នុងហេតុការណ៍ ឬជាសាក្សីដែលមិនសហការនោះគឺ អាចធ្វើឱ្យមានផលលំបាកដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស្តាប់ចម្លើយផងដែរ។

**១.១.២.ការបាត់បង់ភស្តុតាង ឬវត្ថុតាង**

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានកំណត់នូវបទល្មើសរួច ថាជាប្រភេទបទល្មើសជាក់ស្តែង ឬជាបទល្មើសបឋមណាមួយនោះមន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការស្វែងរកភស្តុតាងទៅតាមកន្លែងកើតហេតុដើម្បីកំណត់អត្តសញ្ញាណរបស់ជនល្មើស ផ្ទុយទៅវិញប្រសិនមន្ត្រីនគរបាលយុត្តិធម៌មានភាពយឺតយ៉ាវក្នុងការចុះស៊ើបអង្កេតនោះអាចនឹងធ្វើឱ្យមានការបាត់បង់ភស្តុតាងណាមួយនៅត្រង់កន្លែងកើតហេតុបាន។ បើក្នុងការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌មិនអាចរកនូវវត្ថុតាង ឬភស្តុតាងដែលអាចសម្គាល់ថាមានភាពពាក់ព័ន្ធនឹងជនល្មើសណាមួយនោះទេ ដូចច្នេះមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការកំណត់នៅអត្តសញ្ញាណនៃជនល្មើស ក៏ដូចជាមិនអាចធ្វើកំណត់ហេតុជូនព្រះរាជអាជ្ញាបាន ហើយដំណើរការនៃការស៊ើបអង្កេតអាចមានភាពអូសបន្លាយយូរ។ មូលហេតុនៃការបាត់បង់នូវភស្តុតាង ឬវត្ថុតាងនៅកន្លែងកើតហេតុ គឺអាចបណ្តាលមកពីកត្តាចំនួន ៣ (បី) គឺ៖

- **កត្តាប្រជាពលរដ្ឋ** ៖ កត្តាប្រជាពលរដ្ឋក៏អាចធ្វើឱ្យមានការបាត់បង់នៅភស្តុតាងណាមួយដោយអចេតនាផងដែរ។ ដោយករណីជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាយើង ប្រជាពលរដ្ឋមួយចំនួននៅពេលមានហេតុការណ៍ណាមួយកើតឡើងគឺ តែងតែធ្វើការចោមរោម នៅកន្លែងកើតហេតុហើយអាចធ្វើឱ្យមានការបាត់បង់នៅភស្តុតាងសំខាន់ៗមួយចំនួនដោយ ដែលចាំបាច់នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌សម្រាប់កំណត់អត្តសញ្ញាណនៃជនល្មើស។
- **កត្តាធម្មជាតិ** ៖ នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ កត្តាធម្មជាតិជាបញ្ហាប្រឈមមួយដល់ការបំពេញតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ចុះទៅកន្លែងកើតហេតុធ្វើការស៊ើបអង្កេតស្វែងរកភស្តុតាងដើម្បីកំណត់ប្រភេទនៃបទល្មើសណាមួយដែលកើតមានឡើង។ ប៉ុន្តែក្នុងការចុះស៊ើបអង្កេតនៅកន្លែងកើតហេតុមួយចំនួនរបស់មន្ត្រីនគរបាលយុត្តិធម៌បានទទួលរងនៅកត្តាធម្មជាតិដែល

អាចធ្វើឱ្យមានការបាត់បង់នៅភស្តុតាង។ ក្នុងករណីជាក់ស្តែងអំពីបទល្មើសឧក្រិដ្ឋមួយចំនួនដែលជនល្មើសបានបន្សល់ទុកនៅស្លាកស្នាមម្រាមដៃ ឬដានឈាម ប៉ុន្តែកត្តាធម្មជាតិមួយចំនួនដូចជាមានភ្លៀងធ្លាក់ធ្វើឱ្យបាត់បង់នៅស្លាកស្នាមម្រាមដៃ ឬដានឈាមជាហេតុបណ្តាលមន្ត្រីនគរបាលយុត្តិធម៌មិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើសបាន និងមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការធ្វើកំណត់ហេតុជូនព្រះរាជអាជ្ញាបានផងដែរ។ មួយវិញទៀតកត្តាធម្មជាតិ ក៏អាចធ្វើឱ្យការចុះស៊ើបអង្កេតនៅកន្លែងកើតហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌មានភាព យឺតយ៉ាវដោយសារកត្តាទឹកភ្លៀង ឬកត្តាខ្យល់ព្យុះជាហេតុបង្កឱ្យមានការលំបាកក្នុងការធ្វើដំណើរទៅកន្លែងកើតហេតុ។

- **កត្តាសត្វ** ៖ នៅពេលដែលមានរឿងក្តី ឬបទល្មើសកើតឡើងនៅក្នុងព្រៃដែល មានសត្វព្រៃរស់នៅច្រើន ក្នុងករណីដែលមានការរាយការណ៍អំពីការជួបប្រទះនឹងសាកសពនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅត្រួតពិនិត្យសាកសព ហើយកំណត់អត្តសញ្ញាណរបស់សាកសពនោះ។ ផ្ទុយទៅវិញបើករណីដែលសាកសពត្រូវបានបំផ្លាញដោយសារសត្វព្រៃ ហើយបណ្តាលឱ្យមានការខូចរូបរាងនៃសាកសព នោះជាហេតុធ្វើឱ្យមិនអាចកំណត់ប្រភេទនៃបទល្មើស ឬមូលហេតុនៃការស្លាប់របស់សាកសព និងមិនអាចកំណត់អត្តសញ្ញាណរបស់សាកសពបាន។[៣១]

## ១.២.កត្តាមធ្យោបាយក្នុងការចុះស៊ើបអង្កេត

ក្នុងការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីដែលមានការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬការស៊ើបអង្កេតបទល្មើសបឋម គ្រប់ការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវការនូវមធ្យោបាយផ្សេងៗដូចជា មធ្យោបាយធ្វើដំណើរ សម្ភារៈ និងថវិកា ដើម្បីជួយសម្រួលដល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយចាំបាច់ត្រូវមានបច្ចេកវិទ្យាខាងផ្នែកវិទ្យាសាស្ត្រ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការកំណត់នូវអត្តសញ្ញាណរបស់ជនល្មើសបានច្បាស់លាស់ ចាប់ជនល្មើស និងមានភាពងាយស្រួលដល់ការប្រមូលយកភស្តុតាងបានគ្រប់គ្រាន់។

### ១.២.១.មធ្យោបាយសម្ភារៈសម្រាប់ធ្វើការស៊ើបអង្កេត

មធ្យោបាយជាសម្ភារៈសម្រាប់ធ្វើការស៊ើបអង្កេត គឺជាឧបករណ៍ខាងផ្នែកវិទ្យាសាស្ត្រសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញក្នុងការស្រាវជ្រាវរកភស្តុតាង ឬការពិនិត្យភស្តុតាង ដូចជាឧបករណ៍សម្រាប់ការធ្វើកោសលវិច្ច័យដែលបង្គាប់ដោយចៅក្រមស៊ើបសួរ។[៣២] ចំពោះមធ្យោបាយជាសម្ភារៈសម្រាប់ធ្វើការស៊ើប

[៣១] ប្រសាសន៍របស់ ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង រស់ សារិទ្ធ ប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៦២។

អង្កេតនេះដែរ ក៏អាចជាបញ្ហាប្រឈមមួយនៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយយើងដឹងហើយថាប្រទេសកម្ពុជាយើងគឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ ហើយថវិកាជាតិគឺនៅមានកម្រិត ដូច្នេះហើយចំពោះសម្ភារៈខាងបច្ចេកវិទ្យាគឺមិនទាន់មានភាពជឿនលឿននៅឡើយ។ មួយវិញទៀតចំពោះការស៊ើបអង្កេត គឺពឹងផ្អែកទៅលើតែចម្លើយសារភាពដែលបានមកពីជនជាប់ចោទប៉ុណ្ណោះ ទើបធ្វើឱ្យការស៊ើបអង្កេតមួយចំនួននៅមានភាពខ្វះចន្លោះ។[៣៣] លើសពីនេះទៅទៀតនៅពេលដែលមិនមានសម្ភារៈគ្រប់គ្រាន់នោះមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីជំនាញក្នុងការធ្វើកោសលវិច្ឆ័យមិនអាចកំណត់មូលហេតុនៃបទល្មើសបាន ហើយអាចធ្វើឱ្យមានការកកស្ទះនៅសុំណុំរឿង កំណត់ហេតុដែលមិនអាចជូនដល់ព្រះរាជអាជ្ញាបាន។

### ១.២.២.មធ្យោបាយក្នុងការធ្វើដំណើរដើម្បីចុះទៅកន្លែងកើតហេតុ

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានបណ្តឹងពីប្រជាពលរដ្ឋ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំណាត់ការបន្តពីការដាក់បណ្តឹងនោះ គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចាប់ផ្តើមការចុះស៊ើបអង្កេតភ្លាមៗ ដោយត្រូវចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការស៊ើបអង្កេតក្នុងនោះមធ្យោបាយធ្វើដំណើរដើម្បីធ្វើការចុះស៊ើបអង្កេត គឺពិតជាមានភាពចាំបាច់ជាខ្លាំងដែលអាចសម្រួលដល់ការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងអាចចុះទៅកន្លែងកើតហេតុទាន់ពេលវេលា ហើយអាចនឹងចាប់ខ្លួនជនល្មើសបានទាន់ពេល។ ដូច្នេះហើយប្រសិនបើមិនមានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់នោះទេ ការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាល គឺមិនអាចចាប់ខ្លួនជនល្មើសបានទាន់ពេល ក៏ដូចជាអាចនឹងបាត់បង់នៅភស្តុតាងដោយប្រការណាមួយបាន។

### ១.២.៣.កត្តាថវិកា

កត្តាថវិកាជាមធ្យោបាយមួយយ៉ាងសំខាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការជួយសម្រួលដល់ការបំពេញតួនាទីក៏ដូចជាការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ ដោយសារនៅរាល់ដំណាក់កាលនីមួយៗនៃការស៊ើបអង្កេត និងរាល់ការបំពេញតួនាទីរបស់មន្ត្រីគ្រប់រូប គឺត្រូវមានថវិកាក្នុងការសម្រួលដល់ដំណើរការនៃនីតិវិធីផងដែរ។ ដោយគិតរួមទាំងសោហ៊ុយក្នុងការធ្វើដំណើរ សោហ៊ុយស្បៀងអាហារ និងសោហ៊ុយក្នុងការស្នាក់នៅ ដូចជានៅក្នុងករណីជាក់ស្តែងអំពីការស៊ើបអង្កេតបទល្មើសបឋម ឬការស៊ើបអង្កេតមិនជាក់ស្តែងជាដើម។ ពិសេសជាងនេះទៅទៀតគឺថវិកាសម្រាប់ក្នុងការទិញឧបករណ៍ធ្វើ កោសលវិច្ឆ័យរបស់មន្ត្រីនគរបាលជំនាញខាងផ្នែកវិទ្យាសាស្ត្រ និងមានការចំណាយផ្សេងៗបន្ថែមពីលើទៀតដែលអាចមានក្នុងករណីបន្ទាន់។ ទាំងនេះជាបញ្ហាប្រឈមខាងផ្នែកថវិការបស់មន្ត្រីនគរបាលយុត្តិធម៌ដែលតែងតែមានភាព

[៣៣] ប្រសាសន៍របស់ ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង រស់ សារិទ្ធ ប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

ខ្វះខាតខាងផ្នែកឧបករណ៍វិទ្យាសាស្ត្រ ថវិកានៃការចុះស៊ើបអង្កេត ដែលអាចបណ្តាលឱ្យការបំពេញតួនាទីមិនបានពេញលេញ។

## ១.៣.កង្វះធនធានរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្នុងការទទួលបាននីតិសម្បទាដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមន្ត្រីនគរបាលយុត្តិធម៌គ្រប់រូបត្រូវធ្វើការឆ្លងកាត់នូវការប្រឡងប្រជែងជាមុនសិន។ ហើយនៅពេលដែលទទួលបាននីតិសម្បទាក្លាយមន្ត្រីនគរបាលយុត្តិធម៌រួចរាល់ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តនូវតួនាទីរបស់ខ្លួន ដែលជាការចុះស៊ើបអង្កេតនៅបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុជាដើម។ ក្នុងនោះផងដែរកង្វះធនធានរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រង់ចំណុចនេះគឺចង់ សំដៅទៅដល់កង្វះសមត្ថភាព ក៏ដូចជាកង្វះនៅជំនាញ និងបទពិសោធរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលអាចជួបនៅបញ្ហាប្រឈមនៅក្នុងការអនុវត្តតួនាទី។

### ១.៣.១.កង្វះសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

ការខ្វះខាតសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌គឺជាចំណុចសំខាន់មួយដែលធ្វើឱ្យមន្ត្រីនគរបាលយុត្តិធម៌ មិនអាចបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អគ្រប់គ្រាន់ ដោយយើងដឹងហើយថាក្នុងករណីដែលបទល្មើសនោះជាបទល្មើសជាក់ស្តែងមន្ត្រីនគរបាយុត្តិធម៌នឹងអាចមានអំណាចក្នុងការអនុវត្តតួនាទីបានច្រើនជាងបទល្មើសបឋម។ ប៉ុន្តែក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌មានការខ្វះខាតនូវសមត្ថភាពក្នុងការកំណត់បទល្មើសបានថា ជាបទល្មើសជាក់ស្តែងឬ បទល្មើសបឋមដោយមានភាពស្រពិចស្រពិលក្នុងការសម្រេចនោះ អាចនឹងធ្វើឱ្យការកំណត់ប្រភេទនៃបទល្មើសខុស ហើយរាល់ការអនុវត្តបេសកកម្ម និងដំណើរនៃការអនុវត្តច្បាប់ទាំងអស់របស់មន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវចាត់ទុកជាមោឃៈ។[៣៤]ម្យ៉ាងវិញទៀតនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ខ្វះខាតនូវសមត្ថភាពនៅក្នុងការបំពេញតួនាទីរបស់ខ្លួន តួយ៉ាងដូចជាការស៊ើបអង្កេតចំពោះបទល្មើសជាក់ស្តែង ដោយមានរយៈពេលនៃការស៊ើបអង្កេតត្រឹមតែ ៧ (ប្រាំពីរ) ថ្ងៃ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌មិនអាចបញ្ចប់ការស៊ើបអង្កេតបទល្មើសជាក់ស្តែងនោះនៅក្នុងរយៈពេលដែលបានកំណត់តាមបទប្បញ្ញត្តិនៃច្បាប់ នោះបទល្មើសជាក់ស្តែងនឹងត្រូវបង្វែរទៅជាបទល្មើសបឋមវិញ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើទៅព្រះរាជអាជ្ញា ដើម្បីប្តូរពីការស៊ើបអង្កេតបទល្មើសជាក់ស្តែងទៅជាការស៊ើបអង្កេតបទល្មើសបឋម ដែលធ្វើឱ្យការស៊ើបអង្កេតមានភាពអូសបន្លាយរយៈពេលវែង នាំឱ្យមានការកកស្ទះនៅសំណុំរឿងក្តី និងមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើសបាន។

[៣៤] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី ២៤ខែ មិថុនា ឆ្នាំ ២០១៦។

### ១.៣.២.កង្វះបទពិសោធន៍ ឬកង្វះជំនាញ

ក្នុងការក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ ជាគោលការណ៍ត្រូវមានការប្រឡងប្រជែងជាមុនសិន ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។ ប៉ុន្តែយើងដឹងហើយថាប្រទេសកម្ពុជាបានឆ្លងកាត់នៅសង្គ្រាមជាច្រើនឆ្នាំ ទើបធ្វើឱ្យប្រទេសយើងបាត់បង់នៅសណ្តាប់ធ្នាប់ក្នុងសង្គម ដូច្នេះហើយបន្ទាប់ពីបញ្ចប់សង្គ្រាមប្រទេសកម្ពុជាបានធ្វើការរៀបចំសណ្តាប់ធ្នាប់ក្នុងសង្គមឡើងវិញ ដោយមានការបង្កើតនៅក្រសួង និងស្ថាប័នអនុវត្តច្បាប់គ្រប់ជាន់ថ្នាក់។ ជាមួយគ្នានេះដែរមន្ត្រីនគរបាលយុត្តិធម៌ក៏ជាចំណែកមួយនៅក្នុងការរៀបចំសណ្តាប់ធ្នាប់ក្នុងសង្គមឡើងវិញផងដែរ។ ដោយបញ្ហាសង្គ្រាមនេះហើយទើបធ្វើ ឱ្យមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនត្រូវបានជ្រើសរើសចូលបម្រើការងារ ដោយមិនបានឆ្លងកាត់ការប្រឡងប្រជែង ដោយហេតុនេះហើយទើបមានមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនខ្វះខាតនៅបទពិសោធន៍ក៏ដូចជាជំនាញនៅក្នុងការស៊ើបអង្កេត។ មួយវិញទៀតភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនដែលត្រូវបានកើតឡើងដោយការចាត់តាំង ដែលកើតចេញពីកងរាជអាវុធហត្ថ ឬយោធិន៍នៃក្រសួងការពារជាតិដោយ មិនមានបទពិសោធន៍គ្រប់គ្រាន់នៅក្នុងការស៊ើបអង្កេត ដូច្នេះហើយទើបធ្វើឱ្យការស៊ើបអង្កេតអាចជួបប្រទះនៅបញ្ហាប្រឈមមួយចំនួននៅពេលដែលចុះអនុវត្តបេសកកម្ម។[៣៥]

### ១.៣.៣.ការអនុវត្តខុសនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងការអនុវត្តខុសនៅនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌នេះដែលក៏អាចជាផ្នែកមួយផងដែរ នៅក្នុងការបង្កឱ្យមាននូវបញ្ហាប្រឈមនៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនរគរបាលយុត្តិធម៌។ ដោយយើងដឹងហើយថានៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានប្រព្រឹត្តខុសនីតិវិធី ឬកំហុសណាមួយក្នុងពេលបំពេញការងារ ឬបេសកកម្ម គឺមន្ត្រីនគរបាលយុត្តិធម៌នឹងទទួលនៅទណ្ឌកម្មខាងវិន័យដែលច្បាប់បានប្បញ្ញត្តិដោយយោងទៅតាមមាត្រា ៦៤ និងមាត្រា ៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[៣៦] មួយវិញទៀតការប្រព្រឹត្តកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលបំពេញមុខងារអាចកើតមានឡើងនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការចុះឆែកឆេរដែលមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌក្នុងមាត្រា ៩១ កថាខណ្ឌទីបីបានចែងថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមធ្វើការឆែកឆេរ មុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយលើកលែងតែ ៖

- ក្នុងករណីដែលមានចែងដោយមាត ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិម ជាក់ស្តែង) នៃក្រមនេះ
- ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ
- ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

[៣៥] ប្រសាសន៍របស់ វរសេនីយ៍ទោ អ៊ិន រស់វិទ្យា អនុប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

[៣៦] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៦៤ និងមាត្រា៦៥។

- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរចែកចាយ

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការឆែកឆេរផ្ទុយទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌ ផ្អែកតាមមាត្រា ៩១ ដែលបានលើកឡើងខាងលើនេះ នោះរាល់ភស្តុតាងទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានប្រមូលមកនោះនឹងត្រូវចាត់ទុកជាមោឃៈជាហេតុដែលបង្កឱ្យមានភាពយឺតយ៉ាវនៅក្នុងការបំពេញតួនាទីក៏ដូចជាភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌។[៣៧]

## ផ្នែកទី២៖ ដំណោះស្រាយ

### ២.១.ការពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាចំណុចដ៏សំខាន់មួយដែលត្រូវធ្វើឡើងក្នុងគោលបំណងពង្រឹងនូវជំនាញ និងបទពិសោធន៍បន្ថែមដល់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យគ្រប់សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌អាចយល់ដឹងអំពីដំណាក់កាលនីមួយៗកាន់តែមានភាពច្បាស់លាស់ក្នុងការចុះស៊ើបអង្កេត និងបំពេញនៅតួនាទី ក៏ដូចជាបំពេញបេសកកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាពនិងគុណភាព។ លើសពីនេះទៅទៀតគឺចង់ពង្រឹងសមត្ថភាពក្នុងកិច្ចសហប្រតិបត្តការអនុវត្តច្បាប់រវាងស្ថាប័នអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌  ដើម្បីពង្រឹងតួនាទីភារកិច្ច បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបង្ក្រាបបទល្មើសកសាងសុំណុំរឿងទៅតុលាការ  និងការដោះស្រាយបញ្ហានានាក្នុងការអនុវត្តនីតិវិធីច្បាប់។

#### ២.១.១.ការបើកវគ្គបណ្តុះបណ្តាល

ក្នុងការពង្រឹងបន្ថែមនូវសមត្ថភាព និងចំណេះដឹងដល់មន្ត្រីនគរបាលយុត្តិធម៌គ្រប់ជាន់ថ្នាក់ ដោយការបើកវគ្គបណ្តុះបណ្តាលត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីផ្តល់ចំណេះដឹងបន្ថែមដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តនូវនីតិវិធីច្បាប់ផ្សេងៗ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងតួនាទីភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌។ ហើយនៅក្នុងការបើកវគ្គបណ្តុះបណ្តាលនេះដែរ គឺចង់ពង្រឹងបន្ថែមនៅការអនុវត្តច្បាប់ឱ្យកាន់តែមានភាពច្បាស់លាស់ ពេលចុះបង្ក្រាបបទល្មើស និងការចុះធ្វើការស៊ើបអង្កេតបទល្មើស។ លើសពីនេះទៅទៀតក៏មានការបង្ហាញនៅចំណុចសំខាន់ៗនៃការស៊ើបអង្កេត និងការបង្ហាញបន្ទាប់បន្សំពីបច្ចេកទេសនៃការស្វែងរកភស្តុតាងដែលត្រូវការប្រើប្រាស់ឧបករណ៍វិទ្យាសាស្ត្រក្នុងការស្វែងរកភស្តុតាងដែលជាស្នាមម្រាមដៃឬដានឈាមជាដើម។ ហើយត្រូវមានការបង្ហាត់បង្ហាញអំពីរបៀបនៃការធ្វើកោសលវិច្ច័យទៅលើភស្តុតាងដែល

---

[៣៧] ប្រសាសន៍របស់ ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង រស់ សារិទ្ធ ប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

ទទួលបាន និងមានការផ្ដោតសំខាន់ទៅលើការកំណត់ប្រភេទនៃបទល្មើស រួមទាំងនីតិវិធីព្រហ្មទណ្ឌក្នុងការអនុវត្តច្បាប់ឱ្យមានភាពរលូនដោយមិនមានភាពស្រពិចស្រពិលក្នុងការកំណត់ប្រភេទនៃបទល្មើស និងបានយល់ដឹងពីនីតិវិធីព្រហ្មទណ្ឌកាន់តែច្បាស់។ លើសពីនេះទៅទៀតនៅក្នុងវគ្គបណ្ដុះបណ្ដាលត្រូវមានធ្វើការលើកឡើងអំពីបទពិសោធន៍នៃការអនុវត្តនីតិវិធីព្រហ្មទណ្ឌ និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាបញ្ហាប្រឈម វិធីការពារ និងដំណោះស្រាយចំពោះមុខដែលអាចកើតមានឡើងក្នុងអំឡុងពេលចុះបង្ក្រាបបទល្មើស ឬក្នុងអំឡុងពេលចុះស៊ើបអង្កេតបទល្មើសជាដើម។[៣៨]

### ២.១.២.តាមរយៈការធ្វើសិក្ខាសាលា

ការធ្វើសិក្ខាសាលា ជាផ្នែកមួយនៅក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ដោយអាចបន្ថែមនៅចំណុចខ្វះខាតរបស់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ តាមរយៈការផ្ដល់នូវអនុសាសន៍ និងការចែករំលែកនៅបទពិសោធន៍ថ្មីៗឱ្យមន្ត្រីនគរបាលយុត្តិធម៌បានយល់ដឹងកាន់តែច្បាស់អំពីការអនុវត្តច្បាប់ និងអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌អនុវត្តច្បាប់កាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព។ ក្នុងនោះក៏មានការផ្ដល់នូវទ្រឹស្ដីដែលពាក់ព័ន្ធ និងការអនុវត្តផ្ទាល់ដែលរួមមានការបង្ហាញចំណុចសំខាន់ៗដូចជា ការកំណត់ប្រភេទនៃបទល្មើសថាជាបទល្មើជាក់ស្ដែង ឬជាបទល្មើសបឋម និងមានការផ្ដោតសំខាន់ទៅលើនីតិវិធីក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យការប្រតិបត្តិកាន់តែមាន ភាពរលូន។[៣៩]

## ២.២.ផ្ដល់ជំនួយបន្ថែមលើគ្រប់មធ្យោបាយនៃការស៊ើបអង្កេត

ជាទូទៅនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ មិនថាការចុះស៊ើបអង្កេតបទល្មើសជាក់ស្ដែង ឬបទល្មើសបឋមនោះទេ គ្រប់ការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីជំនាញផ្សេងបានធ្វើការចុះទៅស៊ើបអង្កេតនៅកន្លែងកើតហេតុ ដើម្បីធ្វើកំណត់ហេតុនៃបទល្មើស និងកំណត់ប្រភេទនៃបទល្មើស ដោយធ្វើការស្វែងរកនៅភស្ដុតាង និងកំណត់អត្តសញ្ញាណនៃជនល្មើស ក្នុងករណីមានបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុជាដើម។ ដូច្នេះហើយគ្រប់មធ្យោបាយក្នុងការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានសារៈសំខាន់ណាស់ ពីព្រោះការផ្ដល់ជំនួយដល់មធ្យោបាយផ្សេងៗមិនថា ជាមធ្យោបាយក្នុងការចុះស៊ើបអង្កេត ឬមធ្យោបាយជាឧបករណ៍នៃការស៊ើបអង្កេតនោះទេក៏អាចធ្វើឱ្យការស៊ើបអង្កេតរបស់ មន្ត្រីនគរបាលយុត្តិធម៌មានភាពឆាប់រហ័យ និងអាចដំណើរការនៃការប្រតិបត្តិការបានយ៉ាងរលូនផងដែរ។ ក្នុងនោះ

[៣៨] ប្រសាសន៍របស់ ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង រស់ សារិទ្ធ ប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

[៣៩] ប្រសាសន៍របស់ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្ងៃទី២៦ មិថុនា ឆ្នាំ២០១៩ នៅសាលមហោស្រពកោះពេជ្រ។

ក៏ដែរអាចជួយដល់ការកំណត់ប្រភេទនៃបទល្មើសបានត្រឹមត្រូវ ឬកំណត់អត្តសញ្ញាណរបស់ជនល្មើសបាន និង មិនមានភាពយឺតយ៉ាវពេលធ្វើការចុះស៊ើបអង្កេតទៅតាមកន្លែងកើតហេតុ។

**២.២.១.ជំនួយខាងថវិកា**

នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីដែលបទល្មើសកើតឡើងនៅតាមជនបទ ឬនៅឆ្ងាយ និងករណីមួយទៀតដែលបទល្មើសមានភាពអូសបន្លាយរយៈពេលយូរ ដែលមិនទាន់អាចកំណត់នៅអត្តសញ្ញាណរបស់ជនល្មើសបាននោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតរហូតអាចកំណត់អត្តសញ្ញាណរបស់ជនល្មើស និងធ្វើកំណត់ហេតុជូនទៅព្រះរាជអាជ្ញាបាន។ ដូច្នេះហើយការចុះស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌នេះក៏ត្រូវមានការចំណាយផ្សេងៗនៃការចុះស៊ើបអង្កេតដែលរួមមាន ស្បៀងអាហារ ទីកន្លែងស្នាក់នៅ ក្នុងករណីដែលមិនមានទីកន្លែងស្នាក់នៅសម្រាប់មន្ត្រីនគរបាលដែលចុះទៅស៊ើបអង្កេត (ប៉ុស្ដិ៍នគរបាល ឬទីស្នាក់ការផ្សេងៗ)។ នេះជាហេតុត្រូវតែមានការផ្ដល់ជំនួយបន្ថែមលើផ្នែកថវិកា គឺអាចសម្រួលដល់សកម្មភាពនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌បានយ៉ាងល្អផងដែរ។

**២.២.២.ជំនួយខាងសម្ភារៈ**

យើងដឹងហើយថាប្រទេសកម្ពុជា ជាប្រទេសដែលកំពង់អភិវឌ្ឍនៅក្នុងវិស័យផ្សេងៗ ក្នុងនោះដែរវិស័យដែលទាក់ទងទៅនឹងខាងផ្នែកវិទ្យាសាស្ត្រមួយចំនួន គឺមិនទាន់មានភាពជឿនលឿនខ្លាំងនោះទេ។ ដែលក្នុងវិស័យខាងផ្នែកបច្ចេកវិទ្យាក៏ត្រូវបានប្រើប្រាស់នៅលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ដែលក្នុងនោះក៏មានវិស័យយុត្តិធម៌ដែលមានតួនាទីក្នុងការការពារសណ្ដាប់ធ្នាប់នៅក្នុងប្រទេសជាតិ។ នៅក្នុងវិស័យយុត្តិធម៌ យើងបានលើកយកតួនាទីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញក្នុងការធ្វើកោសល់វិច្ច័យ។ នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចំណុចដែលសំខាន់ជាងគេនោះគឺការកំណត់នៅប្រភេទនៃបទល្មើសបានច្បាស់លាស់ ថាជាបទល្មើសជាក់ស្ដែង ឬជាបទល្មើសបឋម និងអត្តសញ្ញាណរបស់ជនល្មើស។ ហើយក្នុងការកំណត់អំពីប្រភេទនៃបទល្មើស ឬអត្តសញ្ញាណរបស់ជនល្មើសបានលុះត្រាតែមន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញធ្វើការពិនិត្យ ឬធ្វើកោសលវិច្ច័យលើភស្តុតាងដែលទទួលបាន ដើម្បីកំណត់ប្រភេទនៃបទល្មើសនោះ។ ដែលក្នុងនោះដែរគឺត្រូវការប្រើប្រាស់នៅឧបករណ៍ ដើម្បីកំណត់អត្តសញ្ញាណរបស់ជនល្មើស និងកំណត់ប្រភេទនៃអំពើល្មើសនោះបាន។ នេះហើយជាហេតុនៃការផ្ដល់ជំនួយទៅលើផ្នែកសម្ភារៈបច្ចេកវិទ្យាផ្សេងៗដែលរួមមានឧបករណ៍ក្នុងការពិនិត្យ ឬឧបករណ៍សម្រាប់ធ្វើកោសលវិច្ច័យទៅលើភស្តុតាងជាដានឈាម ឬស្នាមម្រាមដៃ គឺមានសារៈសំខាន់ដែលអាចសម្រួលនៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងងាយស្រួលក្នុងការកំណត់អត្តសញ្ញាណនៃជនល្មើស និងប្រភេទនៃអំពើល្មើសបានយ៉ាងច្បាស់លាស់។

## ២.៣.យន្តការពង្រឹងការអនុវត្តច្បាប់

យន្តការពង្រឹងការអនុវត្តច្បាប់ គឺជាការបង្ហាញអំពីការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយមិនមានភាពលំអៀង និទណ្ឌភាព ភាពស្មើគ្នាចំពោះមុខច្បាប់ និងការលុបបំបាត់នៃអំពើពុករលួយពេលអនុវត្តច្បាប់។

### ២.៣.១.ការលុបបំបាត់អំពើពុករលួយ

ជាគោលការណ៍ ការលុបបំបាត់អំពើពុករលួយមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តអំពើអបាយមុខ អំពើពាលាអាវ៉ាសែ ដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួនទៅការពារបទល្មើស ដូចជាការពារជនប្រព្រឹត្តសកម្មភាព ចាប់ជំរិត លួច ឆក់ប្លន់កេងប្រវ័ញ្ចសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមគំហែងទៅលើប្រជាពលរដ្ឋ ដើម្បីការពារជនល្មើស និងប្រើប្រាស់សម្ភារះរបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួនព្រមទាំងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗដែលផ្ទុយនឹងច្បាប់ ហើយមិនត្រូវលាក់សំណុំរឿង វត្ថុតាង ឬធ្វើការដោះដូរនូវវត្ថុតាងដើម្បីប្រយោជន៍បុគ្គលណាមួយឡើយ។

### ២.៣.២.ការលុបបំបាត់វប្បធម៌ការអន្តរាគមន៍

បរិបទនៃសង្គមខ្មែរយើង តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ ហើយជាទម្លាប់ ពលរដ្ឋខ្មែរក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គមទៅហើយ។ ប៉ុន្តែបញ្ហាទាំងនេះបានក្លាយជាទម្លាប់មិនអាចកែប្រែបានសូម្បីតែអ្នករត់ម៉ូតូឌុបម្នាក់ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ពេលដែលខ្លួនត្រូវការជា យថាហេតុមិនថាមានរឿងរ៉ាវតូច ឬធំនោះទេតែងតែចូលខ្លួនមកដោះស្រាយបញ្ចប់បញ្ហាដោយមិនទុកឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី និងច្បាប់ឡើយ។ អ្នកដែលមានអំណាចមានឋានៈនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើឱ្យការបំពេញតួនាទីមន្ត្រីនគរបាលយុត្តិធម៌មិនទាន់បានល្អ និងមិនបានប្រកាន់ភ្ជាប់នូវការអនុវត្តច្បាប់ និងមិនមានយុត្តិធម៌នៅក្នុងសង្គម។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះចាំបាច់ត្រូវពង្រឹងតួនាទីភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់មូលដ្ឋានគ្រឹះ។ បើមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់មិនបានប្រតិបត្តិតាមច្បាប់ត្រូវទទួលពិន័យ និងទណ្ឌកម្មជាដាច់ខាត មិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ដែលធ្វើឱ្យមានកំហុសឆ្គងក្នុងការបំពេញតួនាទីនោះទេ។

### ២.៣.៣.ការលុបបំបាត់វប្បធម៌និទណ្ឌភាព

កាលណាគ្មានយុត្តិធម៌នឹងធ្វើឱ្យមាននិទណ្ឌភាពបើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នាចំពោះមុខច្បាប់ឡើយ។ និទណ្ឌភាព គឺគ្មានការចាប់ខ្លួន និងនាំខ្លួនជនប្រព្រឹត្តបទល្មើសមកធ្វើការវិនិច្ឆ័យទោស ពីព្រោះតែមុខ

តំណែងឥទ្ធិពល ឬទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវបញ្ហា ទាំងនេះមន្ត្រីនគរបាលជាតិត្រូវមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗនៅខណៈពេលដែលខ្លួនបានដឹងពីការប្រព្រឹត្តបទល្មើស មិនត្រូវរង់ចាំឱ្យនរណាម្នាក់ធ្វើពាក្យបណ្តឹងជាមុននោះទេមុនពេលដែលខ្លួនចាប់ផ្តើមស៊ើបអង្កេត។

ជាគោលការណ៍បើមានបទល្មើសព្រហ្មទណ្ឌកើតឡើង ទោះបីជាគ្មានបណ្តឹងក៏ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើកការស៊ើបអង្កេតស្រាវជ្រាវស្វែងរកជនប្រព្រឹត្តបទល្មើស ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ បើមិនដូច្នេះទេបញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់តែមានច្រើនឡើងៗធ្វើឱ្យសង្គមមានភាពច្របូកច្របល់ គ្មានសណ្តាប់ធ្នាប់ គ្មានសន្តិភាព។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាអំពីតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលច្បាប់បានផ្តល់នូវសិទ្ធិអំណាចពិសេសជាច្រើនដល់គ្រប់សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ រួមជាមួយនិងការទទួលបាននីតិសម្បទាដើម្បីក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងនោះក៏មានការបង្ហាញពីនីតិវិធីក្នុងការក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ម៉្យាងវិញទៀតយើងក៏បានសិក្សាបន្ថែមលើបញ្ហាប្រឈម ក៏ដូចជាដំណោះស្រាយរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ក្នុងដំណើរការស៊ើបអង្កេតនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌ត្រូវពិនិត្យឱ្យបានច្បាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ពីព្រោះបើការស៊ើបអង្កេតណាមួយមិនសមស្របទៅនឹងនីតិវិធីដែលមានចែងក្នុងច្បាប់ពេលនោះការស៊ើបអង្កេតនឹងត្រូវក្លាយជាមោឃៈ។

ការអនុវត្តនៅឧក្រិដ្ឋឋាន ក៏ជាបេសកកម្មពិសេសរបស់មន្ត្រីនគរបាលផងដែរ ក្នុងការប្រមែប្រមូលភស្តុតាង ស្លាកស្នាម ឬតម្រុយដោយការប្រើប្រាស់ឧបករណ៍ក្នុងការស្វែងរកភស្តុតាង ឬតម្រុយរបស់ជនសង្ស័យដែលអាចឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យនោះ។ បេសកម្មនៅកន្លែងកើតហេតុត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ ជៀសវាងនៅក្នុងការជួបប្រទះនូវបញ្ហាប្រឈមផ្សេងៗនៅកន្លែងកើតហេតុ ហើយត្រូវមានការត្រៀមគ្រប់ឧបករណ៍ក្នុងការចុះស៊ើបអង្កេតផងដែរ ពីព្រោះប្រសិនបើមិនមានការត្រៀមនោះទេគឺអាចខ្វះនៅឧបករណ៍ដែលជាហេតុបង្កឱ្យមាននូវបញ្ហាប្រឈមផ្សេងៗនៅក្នុងអំឡុងពេលនៃការចុះស៊ើបអង្កេត។ មួយវិញទៀតដោយសារតែមិនមានការត្រៀមទុកជាមុននោះវាអាចនឹងបង្កឱ្យមានភាពយឺតយ៉ាវនៅក្នុងការស៊ើបអង្កេត ហើយអាចឈានទៅដល់ការបាត់បងភស្តុតាងដោយសារគ្រោះធម្មជាតិ ឬដោយសារតែប្រជាពលរដ្ឋហើយការបាត់បងទាំងនេះ គឺអាចធ្វើឱ្យមានការបាត់បង់នៅតម្រុយយ៉ាងសំខាន់នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌។

បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅរកមុខជនដែលបានប្រព្រឹត្តបទល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងសង្គមទាំងមូល។ មន្ត្រីនគរបាលមិនត្រូវរំលងនូវនីតិវិធីសាកសួរជនសង្ស័យ និងស្តាប់ចម្លើយសាក្សីឡើយ ព្រោះវាជាសញ្ញាមួយដែលអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការកំណត់អត្តសញ្ញាណជនដែលប្រព្រឹត្តបទល្មើស។ ក្រោយពីស្វែងរកភស្តុតាងដែល បានបន្សល់នៅកន្លែងកើតហេតុការសំភាសន៍ជនសង្ស័យ និងសាក្សីហើយនោះ ប្រសិនបើមានភាពស៊ីសង្វាក់គ្នាពេលនោះមន្ត្រីនគរបាលយុត្តិធម៌អាចចាត់វិធានការ តាមស្វែងរកចាប់ខ្លួន ជនដែលបានប្រព្រឹត្តបទល្មើសដោយមានសេចក្តីសម្រេចពីព្រះរាជអាជ្ញា ឬដោយមានដីកាចាប់ខ្លួនផងដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងទាំងពីរបានធ្វើការស្រាវជ្រាវលើប្រធានបទនៅក្នុងសារណាមួយនេះរួចមក យើងខ្ញុំយល់ឃើញថាប្រធានបទខាងលើនេះពិតជាមានសារៈសំខាន់ដល់មន្ត្រីអនុវត្តច្បាប់ រួមទាំងយើងខ្ញុំទាំងពីរនាក់ផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាប្រធានបទមួយនេះនូវតែមានភាពខ្វះចន្លោះនៅឡើយ ដូច្នេះហើយយើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនលើប្រធានបទនេះ ៖

ជាអនុសាសន៍ យើងខ្ញុំសូមសំណូមពរទៅដល់ប្រជាពលរដ្ឋគ្រប់រូបសូមមេត្តាជួយសហការគ្នា ជាមួយមន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានបទល្មើសកើតឡើង ក្នុងការសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌នោះមានដូចជា ត្រូវតែការរាយការណ៍ផ្តល់ជូនទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានទីតាំងស្ថិតនៅជិតបំផុតនៃកន្លែង ដែលបានកើតហេតុនោះ។

ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋគ្រប់រូបអាចដាក់ពាក្យបណ្តឹងដោយចំហ ឬប្តឹងអនាមិកក៏បានដោយមិនគិតថាប្រជាពលរដ្ឋរូបនោះជាអ្នករងគ្រោះផ្ទាល់ ឬតតីយជន ក្តីគឺមានសិទ្ធិធ្វើពាក្យបណ្តឹងខាងលើបាន។

សូមសំណូមពរដល់គ្រប់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ឱ្យមានការលុបបំបាត់ចោលនូវអំពើពុករលួយជាពិសេសអ្នកធ្វើកំណត់ហេតុ និងអ្នកធ្វើកោសល្យវិច្ច័យ ដើម្បីជម្រុញឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅដោយយុត្តិធម៌យ៉ាងល្អបំផុត។ ជាងនេះទៅទៀត បានជម្រុញឱ្យប្រទេសជាតិមានតម្លាភាព និងមាននីតិរដ្ឋ។

សូមឱ្យមន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយមេត្តាគោរពតួនាទី និងច្បាប់ឱ្យបានហ្មត់ចត់នូវក្រមសីលធម៌ព្រមទាំងគោលការណ៍ទាំងឡាយណាដែលមានចែងក្នុងច្បាប់ឱ្យបានម៉ឺងម៉ាត់ ព្រោះបើមិនបានគោរពទេនោះអាច និងបណ្តាលឱ្យមានការរំលោភនូវសិទ្ធិមនុស្សព្រមទាំងសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ ប្រជាពលរដ្ឋគ្រប់រូប ថែមទាំងធ្វើឱ្យប្រទេសជាតិបាត់បង់នូវនីតិរដ្ឋទាំងស្រុងទៀតផង។

ជាចុងក្រោយយើងខ្ញុំសូមសំណូមពរដល់ រាជរដ្ឋាភិបាលថ្នាក់លើទាំងអស់ សូមជួយផ្គត់ផ្គង់នូវរាល់ដំណើរការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូចជាការផ្គត់ផ្គង់ជាថវិកា ឧបករណ៍ផ្សេងៗក្នុងការធ្វើកោសល្យវិច្ច័យ មធ្យោបាយធ្វើដំណើរពេលចុះស៊ើបអង្កេតនៅកន្លែងកើតហេតុ ដើម្បីឱ្យការអនុវត្តនៅតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ កាន់តែមានភាពឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

# ឯកសារយោង

# **ឯកសារយោង**

## **១. លិខិតបទដ្ឋានគតិយុត្ត**

- ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ សីហា ឆ្នាំ២០០៧។

## **២. សៀវភៅ ឬឯកសារផ្សេងៗ**

- វចនានុក្រម សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន ណាត។
- សៀវភៅនៅ "នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលឆ្នាំ២០០៩"។
- នីតិវិធីព្រហ្មទណ្ឌទូទៅរៀបរៀងដោយ **លោក រុន ពណ្ណារិទ្ធ** និង **លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត** ឆ្នាំ២០១២។
- ដកស្រង់ចេញពីប្រសាសន៍របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ថ្ងៃទី២៦ មិថុនា ឆ្នាំ២០១៩ នៅសាលមហោស្រពកោះពេជ្រ។
- ដកស្រង់ចេញពីខ្លីបវីឌីអូ (វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ) ក្រោមការធ្វើបទបង្ហាញរបស់ **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទីផ្សព្វផ្សាយថ្ងៃទី២០-២៤ខែមិថុនា ឆ្នាំ២០១៦
- ដកស្រង់ចេញពីប្រសាសន៍របស់ **ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង រស់ សារិទ្ធ** ប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។
- ដកស្រង់ចេញពីប្រសាសន៍របស់ **វរសេនីយ៍ទោ អ៊ុន រស់វិទ្យា** អនុប្រធានអាសនៈជំនាញស៊ើបអង្កេតព្រហ្មទណ្ឌនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

# ឧបសម្ព័ន្ធទី១

# គម្រូ

# សញ្ញាបត្រ

# និង

# វិញ្ញាបនបត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

# សញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ១៥៥ ឈ.ស របស់អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីមន្ត្រីនគរបាលដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : កើតថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៥

ឋានន្តរសក្តិ វរសេនីយ៍ទោ អត្តលេខ ០៣៤៨៤ ឋាន: នាយករងសាលានគរបាលជាតិ

អង្គភាព : នាយកដ្ឋានបណ្តុះបណ្តាល

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : វរសេនីយ៍ អៀង ណារី

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ ០៩៥/០៨ ក.ប.ឃ.ន

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១០
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អង្គ វង្សវឌ្ឍនា

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាភូមិន្ទនគរបាល

# វិញ្ញាបនបត្របញ្ជាក់ការសិក្សា

## នាយកសាលាភូមិន្ទនគរបាល

## CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា: .................................... កើតថ្ងៃទី .................................... នៅ ............ ភ្នំពេញ ............

**Certifie que** .................................... **né(e)le** .................................... **à** ............ Phnom Penh ............

បានរៀនចប់វគ្គ ............ វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ............ និទ្ទេស ............ នៅសាលាភូមិន្ទនគរបាល

**a suivi le starge** ............ Classe de formation des Policiers Judiciers ............ **Mention** ............ **à l'Ecole Royale de police**

ចាប់ពីថ្ងៃទី ...២០... ខែ ...មិថុនា... ឆ្នាំ២០០៧ ... ដល់ថ្ងៃទី ...២២... ខែ ...មិថុនា... ឆ្នាំ២០០៧ ... ។

**du** ............ 20 June 2007 ............ **au** ............ 22 June 2007 ............

វិញ្ញាបនបត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន ។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ ថ្ងៃទី ...[illegible]... ខែ ...[illegible]... ឆ្នាំ២០០[illegible]

លេខ: ....................

**Phnom Penh, le** ....................

**នាយកសាលាភូមិន្ទនគរបាល**

**Le directeur de l'École Royale de Police**

[illegible]

ក្រសួងការពារជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

[illegible] ២៥៤/២០១១ ស.ក.ក [illegible] ចុះថ្ងៃទី ២៩ ខែ ២ សីហា ឆ្នាំ ២០១១ [illegible]

[illegible] ៦១ [illegible]

បញ្ជាក់ថា : លោក ង៉ុង សុខលុច កើតថ្ងៃទី ០៥ ខែ ២ កក្កដា ឆ្នាំ ១៩៨០

ឋានន្តរស័ក្តិ : វរសេនីយ៍ត្រី អត្តលេខ ១០៤ ៣៦៥ មុខតំណែង ជំនួយការ ការិយាល័យសន្តិសុខ

អង្គភាព : មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

[illegible] ៦១ [illegible]

[illegible] សញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

[illegible] : លោកវរសេនីយ៍ត្រី ង៉ុង សុខលុច [illegible] ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១១

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ២ កក្កដា ឆ្នាំ ២០១១

លេខ ០៧៣៥/១១ [illegible]

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ.វង្សវឌ្ឍនា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រ

## វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី ១៦

បញ្ជាក់ថា : លោកវរសេនីយ៍ត្រី **ម៉ាំង សុខឈុច** អត្តលេខ ១០៨ ៣៦៥

តួនាទី ជំនួយការការិយាល័យសន្តិសុខ អ.ហ រាជធានី

